ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 30-Jan-2013, 11:47
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៤នាទី**

**សវនាការលើកទី១៥៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

លោក ស៊ីម៉ុន មេសិនប៊ឺជ
*(Mr. Simon MEISENBERG)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

កញ្ញា អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក វ៉េន ពៅ

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក អាង ឧត្តម | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក អាល់ រ៉ូកូហ្វ (TCW-565) | អង់គ្លេស |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក អាល់ រ៉ុក្កូហ្វ** (TCW-565)

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី៖ ........ ទំព័រ ២
សួរដោយលោក សុន អរុណ ផ្ដើមពី៖ ........ ទំព័រ ១៧
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី៖ ........ ទំព័រ ២៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី អាល់ រ៉ុក្ហូ ដោយភាគីមេធាវីការពារក្តី។

មុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី សូមលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែលោក គង់ សំអុន មេធាវីជាតិការពារក្តីឲ្យលោក ខៀវ សំផន អវត្តមានដោយមូលហេតុមានធុរៈផ្ទាល់ខ្លួន។ ជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការដោយមូលហេតុសុខភាព។ ជនជាប់ចោទ នួន ជា អវត្តមានដោយមូលហេតុសុខភាព និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ ប៉ុន្តែជនជាប់ចោទបានដាក់នូវលិខិតលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការនៃការស្តាប់សក្ខីកម្មសាក្សី អាល់ រ៉ុក្ហូ ដែលនឹងបន្តផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះ ហើយសាក្សីរូបនេះមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការ។ សូមអរគុណ។

[០៩:០៦:៣១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ការលះបង់សិទ្ធិ និងការអវត្តមានរបស់ជនជាប់ចោទ នួន ជា អង្គជំនុំជម្រះបានសម្រេចរួចហើយកាលពីម្សិលមិញ លើសំណើសុំលើនៃការអវត្តមានមិនចូលរួមនៅក្នុងកិច្ចដំណើរការសវនាការ។ ក្នុងករណីនៃការស្តាប់សក្ខីកម្មសាក្សី អាល់ រ៉ុក្ហូ នេះ។

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[០៩:០៧:២០]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមជម្រាបសួរលោក លោកស្រីចៅក្រម លោកប្រធាន ហើយនិងលោកសាក្សី វ៉ុំកូហ្វ។ ខ្ញុំឈ្មោះ កូប៉េ ខ្ញុំជាមេធាវីអន្តរជាតិការពារក្ដីឲ្យលោក នួន ជា។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួរទី១របស់ខ្ញុំ ខ្ញុំសួរទៅលោកថ្ងៃនេះគឺថាតើលោកធ្លាប់បានជួបមន្ត្រីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ដើម្បីសម្ភាសលោកក្នុងឋានៈជាសាក្សីមុនដែលលោកមកទីនេះ?

**លោក អាល់ វ៉ុំកូហ្វ៖**

**ឆ៖** *(គ្មានការបកប្រែ)*

**ស៖** សំណួរខ្ញុំ ថាតើការិយាល័យសហចៅក្រមស៊ើបអង្កេតធ្លាប់បានទៅជួបលោកដែរឬទេកាលពីមុន មិនមែនចំពោះមុខអង្គជំនុំជម្រះទីនេះទេ ប៉ុន្តែយូរមកហើយ គឺថាខាងការិយាល័យសហចៅក្រមស៊ើបអង្កេត ឬក៏អ្នកស៊ើបអង្កេតធ្លាប់បានជួបលោកដែរឬទេ?

[០៩:០៨:២២]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ការសួរសំណួរនេះ គឺថាដោយហេតុថាសាក្សីរូបនេះ គឺថាគាត់មិនបានដឹងពីស្ថាប័នផ្សេងៗនៃតុលាការនេះទេ ហើយខ្ញុំមិនគិតថាសំណួរបែបនេះវាពាក់ព័ន្ធទៅនឹងករណីរឿងក្ដីនេះទេ ពីព្រោះអាហ្នឹងជាកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតដោយឡែក ដែលមិនគប្បីសួរពេលនេះបាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជម្រាបជូនលោកប្រធានថា យើងមានការប៉ុនប៉ងពីមុនរបស់សហចៅក្រមស៊ើបអង្កេតក្នុងការសម្ភាសសាក្សីរូបនេះ ថាតើវាមានការលើកលែងក្នុងវិធានផ្ទៃក្នុងដែរឬទេ ដែលថាមិនមានការសម្ភាសរបស់សហចៅក្រមស៊ើបអង្កេត ថាហេតុអ្វីបានជាមិនមានការសម្ភាសបែបនេះ ដើម្បីឲ្យសាធារណជន

និងអង្គជំនុំជម្រះទីនេះបានជ្រាប ថាហេតុអីបានជាមិនមានបទសម្ភាសរបស់គាត់ពីមុន។

[០៩:០៩:៣៨]

**ប្រធានអង្គជំនុំ៖**

បើមិនច្រឡំទេ គឺអង្គ -- គឺយើងខ្ញុំផ្ទាល់តែម្តង កាលពីម្សិលមិញបានតាំងសំណួរនេះរួចហើយ នៅក្នុងសំណួរពាក់ព័ន្ធនឹងការសួរសាវតារជាតិ ហើយនិងសួរសំណួរពាក់ព័ន្ធថាគាត់ធ្លាប់ផ្តល់សក្ខីកម្ម ដល់មន្ត្រីអ្នកស៊ើបអង្កេតនៃការិយល័យសហចៅក្រមស៊ើបអង្កេតដែរឬអត់? គាត់បានឆ្លើយច្បាស់លាស់ ហើយ។ ដូច្នេះសំណួរនេះគឺជាសំណួរច្រំដែល។ ដូច្នេះសាក្សីមិនចាំបាច់ឆ្លើយតបនឹងសំណួរនេះទេ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួររបស់ខ្ញុំថាតើសហចៅក្រមស៊ើបអង្កេតធ្លាប់បានព្យាយាមជួបគាត់ដែរឬទេ? ខ្ញុំមិនសួរគាត់ថាធ្វើសក្ខីកម្មទេ ប៉ុន្តែខ្ញុំសួរសំណួរផ្សេង។ លោក រ៉ូហ្វ ម្សិលមិញនេះ លោកបានឆ្លើយថា លោកមកភ្នំពេញនៅក្នុងរដូវផ្ការីកនៃឆ្នាំ១៩៧៣ ម្សិលមិញលោកក៏និយាយអំពីការចុងបញ្ចប់នៃការទំលាក់គ្រាប់បែកសហរដ្ឋអាមេរិកនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៣ ផងដែរ។ នៅក្នុងដំណើររបស់លោកនៅក្រៅភ្នំពេញក្នុងឆ្នាំ១៩៧៣ហ្នឹង តើលោកខ្លួនឯងលោកបានឃើញអ្វីខ្លះ? ជាពិសេសការទម្លាក់គ្រាប់បែក បេ-៥២ នោះ នាសម័យនោះ?

**លោក អាល់ រ៉ូក្វហ្វ៖**

**ឆ៖** ខ្ញុំផ្ទាល់មិនបានទទួលបទពិសោធន៍អំពីការទម្លាក់គ្រាប់បែក បេ-៥២ ទេ ប៉ុន្តែខ្ញុំបានឮបាន ឃើញជាពិសេស ឃើញយើង ឃើញសំណល់នៃបំណែកគ្រាប់បែកហើយនិងរណ្តៅជាច្រើននៅកន្លែងមួយចំនួន។ ប៉ុន្តែខ្ញុំមិនរងផលប៉ះពាល់អំពីទម្លាក់គ្រាប់បែកទេ គឺថា ដែលជិតខ្ញុំជាងគេនោះគឺថាអាចនឹងពីរបីគីឡូ ឬក៏៥០គីឡូពីខ្ញុំងណោះ។

[០៩:១១:៥៨]

**ស៖** តើលោកធ្លាប់ជជែកជាមួយអ្នកណាម្នាក់ដែលរងផលប៉ះពាល់ពីការទម្លាក់គ្រាប់បែក បេ-៥២ នេះដែរឬទេ?

**ឆ៖** ខ្ញុំមិនបានសួរទៅជនភៀសខ្លួនដែលបានរងផលប៉ះពាល់នោះទេ។ ជាពិសេសកាកបាទ

ក្រហម និង វើលវីហ្សិន ក៏ខ្ញុំមិនបានសួរដែរ ប៉ុន្តែពួកអង្គការទាំងនោះអាចដឹង។ ពេលខ្លះគឺថា បានជួបប្រទះហេតុការណ៍ហ្នឹងនៅអ្នកលឿងនៅពេលដែលមានអ្នករបួសបានត្រូវគេនាំមកភ្នំពេញ។ ក្នុងឋានៈជាអ្នកថតរូប ខ្ញុំមិនបានសួរសម្ភាសជាលម្អិតជាមួយជនភៀសខ្លួនអស់នោះទេ ខ្ញុំបានទៅជាមួយ ពិតហើយ ខ្ញុំបានទាក់ទងជាមួយមនុស្សដែលរងការភ័យខ្លាចរន្ធត់ពីការទម្លាក់គ្រាប់បែក បេ-៥២ គឺខ្ញុំបានឮពីពួកអ្នកទាំងអស់នោះខ្លះដែរ។

**សៈ** តើលោកបានឃើញពីផលប៉ះពាល់នៃការទម្លាក់គ្រាប់បែកនេះដែរឬទេ? ការបំផ្លាញនូវហេដ្ឋារចនាសម្ព័ន្ធនៅទីក្រុង នៅទីប្រជុំជនជាដើមនោះ?

[០៩:១៣:២៦]

**ឆៈ** ខ្ញុំបានឃើញគឺថាមានស្នាមទម្លាក់គ្រាប់បែកមានការអន្តរាយមួយចំនួនដែរ។

**សៈ** តើលោកអាចរៀបរាប់ឲ្យលម្អិតជាងនេះបន្តិចទេ អ្វីដែលលោកបានឃើញនោះ? ដែលលោកបានជួបផ្ទាល់ ឃើញផ្ទាល់ដែរនោះ?

**ឆៈ** ខ្ញុំមានការលំបាកក្នុងការរៀបរាប់លម្អិតអំពីករណីមួយៗនៃការទម្លាក់គ្រាប់បែក។ ពេលខ្លះវានៅឆ្ងាយ ហើយកម្រិតនៃការទម្លាក់នៅពេលនោះគឺថាពេលខ្លះទម្លាក់ពេលយប់។ ខ្ញុំមានរូបថតក្នុងរយៈពេល២ឆ្នាំ ដែលខ្ញុំនៅទីនោះ ដែលប្រជាជនភៀសខ្លួនមកពីជនបទមកភ្នំពេញរងរបួស ប៉ុន្តែនៅតាមជនបទផ្ទាល់នោះនៅក្បែរៗកន្លែងទម្លាក់គ្រាប់បែក ខ្ញុំមិនបានដឹងច្បាស់ ហើយខ្ញុំក៏មិនបានឃើញដោយផ្ទាល់ភ្នែកហ្នឹង គឺថាខ្ញុំឃើញតែស្នាមដែលកើតពីក្រោយហេតុការណ៍ទម្លាក់តែប៉ុណ្ណោះ។

**សៈ** តើលោកបានធ្វើការថតរូបជាក់លាក់អំពីការទម្លាក់គ្រាប់បែក អំពីផលប៉ះពាល់ ឬក៏ការអន្តរាយពីការទម្លាក់គ្រាប់បែកនោះដែរឬទេ?

[០៩:១៥:០០]

**ឆៈ** ដោយទាក់ទងអំពីការរាយការណ៍ ហើយនិងអំពីបទយកការណ៍ផ្សេងៗនោះ គឺមានឯកសារបានផ្ដល់ទៅឲ្យ អាសូស៊ីអេតធីត ប្រេស ពេលខ្លះគឺថាយើងបានផ្ដល់ព័ត៌មាន ជាពិសេសយើងមានទស្សនាវដ្ដី កាសែតផ្សេងៗ គឺនៅពេលនោះខ្ញុំមានឯកសារមួយចំនួន ដូចជានៅថ្ងៃទី១៥ ខែសីហា គឺការបញ្ឈប់ ហើយមានការកែប្រែអំពីសង្គ្រាមដែលប្រព្រឹត្តទៅ។ អ៊ីចឹងខ្ញុំសូមជម្រាបថា ២ឆ្នាំភាគច្រើនដែលខ្ញុំធ្វើការនោះ គឺថាមិនមានការទម្លាក់គ្រាប់របស់សហរដ្ឋអាមេរិកទេ គឺនៅខែសីហា ឆ្នាំ៧៣ រហូតទៅដល់ខែមេសាដែលខ្ញុំនៅទីនេះ គ្រាន់តែបានដឹងឮស្នូរពីចម្ងាយ។

**ស៖** តើលោកនៅមានហ្វីលថតរូបអំពីរូបភាពទាំងអស់នោះដែរឬទេ រហូតមកដល់ពេលនេះ?

**ឆ៖** បាទ ខ្ញុំមាន។ ខ្ញុំមានហ្វីលរូបទាំងអស់នោះមិនទាន់ផ្តិត ហើយនិងមានស្លាយផងដែរ។ បណ្ណសាររបស់ខ្ញុំគឺនៅសហរដ្ឋអាមេរិក។ ខ្ញុំបាននិយាយយោងពីម្សិលមិញហ្នឹង គឺនៅក្នុងសក្ខីកម្មហ្នឹង អំពីមានករណីខ្លះដែលគិតថារូបថត រូបខ្លះដែលខូចខាតដោយត្រូវទឹក ប៉ុន្តែខ្ញុំមានបានបោះពុម្ពជាច្រើន គឺថារីឯហ្វីលដែលថតហើយនោះមិនបាត់ទេ ខ្ញុំនៅមាននៅឡើយ។

[០៩:១៦:៥១]

**ស៖** លោក រ៉ុក្វហ្វ ម្សិលមិញលោកបញ្ជាក់ថា មានប្រហែលជាជនភៀសខ្លួន២លាន ឬក៏ច្រើនជាងហ្នឹងនៅភ្នំពេញនៅពេលដែលលោកនៅទីនោះ។ តើលោកអាចប្រាប់ខ្ញុំបានទេ ថាតើលោកបានតួលេខហ្នឹងមកណា ដែលថា២លានជាងហ្នឹង?

**ឆ៖** គឺការប្រមាណដោយសង្ខេបហ្នឹង គឺថា២លានហ្នឹង គឺថាមានការពិភាក្សាក្នុងចំណោមបុគ្គលិកអ្នកជនភៀសខ្លួន អ្នកទទួលបន្ទុកផ្នែកហ្នឹង គឺដែលថែទាំផ្តល់ការគាំទ្រដល់ជនភៀសខ្លួន។ ប្រហែលថា ប្រហែលជា ៤០០.០០០នាក់នៃប្រជាជនទីក្រុងភ្នំពេញ ហើយនិងមានជនភៀសខ្លួនបន្ថែមលើហ្នឹងទៀត។ ហើយយើងមានការពិបាកក្នុងការរាប់ដោយផ្ទាល់នោះណាស់ពេលនោះ។ ហើយខ្ញុំបានពិភាក្សាជាមួយគណៈកម្មការកាកបាទក្រហម ហ្នឹងគឺថាអាចមានឯកសារជាច្រើនដែលថា ដែលមានឯកសារ មានទិន្នន័យសម្រាប់ក្រុមគ្រួសារបុគ្គលដែលគេមកពីទីណា សុទ្ធតែទាក់ទងទៅនឹងជនភៀសខ្លួន។ ហើយសកម្មភាពរបស់ អាយ.ស៊ី.អ័រ.អេស នៅជនបទ នៅមន្ទីរពេទ្យនៅកំពង់ឆ្នាំង ខ្ញុំបានទៅទីនោះផងដែរ។ ហើយក្រុមវេជ្ជបណ្ឌិតដែលបានសង្គ្រោះជីវិតខ្ញុំ គឺថាដែលខ្ញុំត្រូវចំណាំងគ្រាប់នោះ។

[០៩:១៨:៣១]

រីឯនៅភ្នំពេញវិញ គឺថាការទម្លាក់គ្រាប់បែក ហើយនិងក៏មានដែរ ហើយក៏មានប្រអប់ឯកសារមួយចំនួនរវាង ដែលគណៈកម្មការធ្វើការ ហើយបញ្ជូនទៅហ្សឺណែវ គឺថាគេបញ្ជាក់ថាមានមនុស្ស១លាននាក់ ដែលមានឯកសារកត់ត្រាត្រឹមត្រូវនោះ។ ដូចដែលខ្ញុំជម្រាបម្សិលមិញហ្នឹងគឺ នៅអូតែលកាំបូឌីយ៉ាណា គឺជាជំរំជនភៀសខ្លួនមួយដែលរើលរីសិនជាអ្នកគ្រប់គ្រង គឺថាមានមនុស្ស២៣.០០០នាក់នៅទីនោះ។ ខ្ញុំមិនបានទទួលតួលេខជាក់លាក់ដោយការរាប់នោះទេ ប៉ុន្តែយើងបានដឹងជាទូទៅពីភ្នាក់ងារផ្សេងៗថាមានប្រហែល២លានជាង។

**ស៖** តើលោកអាចពន្យល់អំពីលក្ខខណ្ឌរស់នៅអំពីរបស់ប្រជាជន ជនភៀសខ្លួន មិនមែន

និយាយតែជំរំជនភៀសខ្លួននៅកាំបូឌីយ៉ាណាកាលណោះទេ ប៉ុន្តែនៅកន្លែងផ្សេងៗទៀត តើជីវភាពការរស់នៅរបស់ពួកគាត់នោះដូចម្តេច?

[០៩:១៩:៤០]

**ផ:** ខ្ញុំបានឃើញជនភៀសខ្លួនជាច្រើនរស់នៅតាមសួនច្បារ នៅតាមតំបន់ផ្សេងៗ។ ប៉ុន្តែខ្មែរក្រហមបានផ្តោងដាក់តំបន់ផ្សេងៗនៅជិតភ្នំពេញ នៅដោយកាំភ្លើងធំ១០៧មីលីម៉ែត្រ។ យើងមានគ្រាប់ផ្តោងធ្លាក់មកនៅផ្នែកខ្លះនៃភ្នំពេញដែលមានជំរំជនភៀសខ្លួន ដែលគេភៀសមករាប់ពាន់ ហើយក៏ចេញពីកន្លែងនេះទៅកន្លែងផ្សេងដើម្បីជៀសគ្រាប់ផ្តោង។ ដើមឈើជាច្រើននៅក្នុងទីក្រុងបានបាក់ ហើយស្លាប់ ហើយក៏ប្រជាជនបានកាប់ដើមឈើនៅក្នុងទីក្រុងដើម្បីធ្វើឧសដុតជាដើម។ ជំរំជនភៀសខ្លួន គឺថានៅជាយៗក្រុងហ្នឹង គឺភាគច្រើនណាស់យើងប្រទះឃើញមានក្រុមគ្រួសារ។ មួយចំនួនច្រើនក៏មិនបានចូលទៅក្នុងជំរំនោះដែរ តាមដែលយើងសង្កេតនោះ។ នេះហើយដែលជាមូលហេតុថា ប្រជាជនជាច្រើនដែលមករស់នៅក្នុង តាមសួនច្បារនៅជិតអូតែល រ៉ូយ៉ាល់ គឺថាមានរាប់រយនាក់ដែលនៅក្នុងតំបន់ដែលថា មានរុក្ខជាតិ មានដើមឈើអីហ្នឹងច្រើន។ ហើយពួកគេក៏បានដើររកចំណីអាហារនៅពាសពេញហ្នឹងដែរ គឺថាមានជនភៀសខ្លួនជាច្រើនដែលថាមិនអាចដាក់បញ្ចូលទៅក្នុងប្រព័ន្ធជនភៀសខ្លួនទាំងអស់បានទេ។

[០៩:២១:១៨]

ហើយនៅក្បែរស្តាតអូឡាំពិកហ្នឹងក៏ដូច្នោះដែរ ហើយខ្ញុំបានថតរូបក្រុមគ្រួសារមួយដែលជនយោធា ដែលមានបុគ្គលមួយចំនួនបានថែទាំគ្រួសារដែល យោធាមួយដែលមានសមាជិកស្លាប់ ហើយមាន -- បាទ ហើយគឺវាខុសពីជំរំជនភៀសខ្លួនធម្មតាហ្នឹង នៅក្រៅហ្នឹងគឺច្រើនណាស់ គឺរស់នៅផ្នែកថ្នាក់ខាងលើមួយនៃស្តាតអូឡាំពិក គឺថាមនុស្សមួយចំនួនរស់នៅទីឡាក៏ត្រូវគេបោះបង់ចោល។ យើងមានក្រុមគ្រួសារនៅក្នុងក្រុងភ្នំពេញ គឺថាយើងសំណាងយើងបានទៅនៅជាមួយក្រុមគ្រួសារ បើយើងអត់ទេ គឺថាមានមនុស្សអត់ផ្ទះសម្បែងហ្នឹងរាប់ពាន់ដើរពាសពេញទីកន្លែង។ ប្រហែលជាថ្ងៃ១៤, ១៥ ខែមេសា ខ្ញុំបានថតរូប គឺថាមនុស្សដែលភៀសខ្លួនរត់ចេញពីការផ្តោងគ្រាប់ហ្នឹង គឺថាគេផ្តោងដាក់ទៅចំកន្លែងមួយដូចគឺថា គេចេញពីតាខ្មៅទៅភូមិភាគខាងជើង គឺថាប្រហែលជារាប់ពាន់នាក់។

ខ្ញុំមិនដឹងចំនួនច្បាស់ទេ ដោយមិនបានរាប់ ប៉ុន្តែពួកគេរត់គេចពីកន្លែងមួយនៃភ្នំពេញទៅទីនោះ បាទ ទៅខាងតាខ្មៅនោះ។ នៅថ្ងៃទី១៧ ខែមេសា ជាទិវានៃការដួលរលំទីក្រុងភ្នំពេញនោះ មនុស្សរាប់

ពាន់ជាជនភៀសខ្លួននៅអូតែលរ៉ូយ៉ាល់ ពួកគេមិនអាចចូលទៅក្នុងទេ។ កាកបាទក្រហមបានប្រកាសថាជាតំបន់អន្តរជាតិ ប៉ុន្តែខ្មែរក្រហមមិនទទួលស្គាល់ទេ ហើយមនុស្សជាច្រើនគឺថាអន្ទះសាចង់ជ្រៀតចូលទៅកន្លែងនោះខ្លាំងណាស់ ប៉ុន្តែមិនអាចចូលបាន។

[០៩:២៣:២៣]

**ស៖** លោក រ៉ុក្ហូ តើលោកអាចជម្រាបតុលាការបានទេ? តើវាមានភាពខុសគ្នាអំពីទស្សនៈនៃស្ថានភាពនៅក្បែរឆ្នាំ១៩៧៥ ខែមេសា ហើយនិងទី១ ដែលលោកមកភ្នំពេញនៅក្នុងរដូវផ្ការីកនៅឆ្នាំ ១៩៧៣ ទាក់ទងទៅនឹងស្ថានភាពទូទៅដែលលោកចងចាំ?

**ឆ៖** ដើម្បីឱ្យជាក់លាក់ដែលខ្ញុំមកភ្នំពេញនោះ គឺថាទី១ ឆ្នាំ១៩៧០ ខ្ញុំចំណាយពេល២ខែនៅកម្ពុជា នៅក្នុងសម័យកាល ដែលសម័យអាមេរិកាំងចូលមកស្រុកនេះ។ ទីក្រុងស្អាតណាស់ គឺមើលទៅល្អឥតខ្ចោះ មិនមានជនភៀសខ្លួនទេ មិនមានអ្វីទាំងអស់ វាជាទីក្រុងស្អាត។ ហើយខ្ញុំត្រឡប់មកកម្ពុជាម្តងទៀតសម្រាប់ពេល ២ឆ្នាំ គឺឆ្នាំ -- ខែមេសា ឆ្នាំ១៩៧៣។ សង្គ្រាមចាប់ផ្តើមហើយគឺមានជនភៀសខ្លួនហ្នឹងមកច្រើន ហើយស្ថាភាពខុសគ្នាស្រឡះកាលពីមុននោះ ខុសពីឆ្នាំ១៩៧០។ យោធា ហើយសង្គ្រាមគឺចាប់ផ្តើមឡើង គឺថាជុំវិញទីក្រុងភ្នំពេញ គឺ៣៦០ដឺក្រេ ជុំវិញទាំងអស់តែម្តង យើងអាចឮ យើងអាចមើលឃើញផ្សែងអីជាដើម។

[០៩:២៤:៤៨]

**ស៖** លោកប្រៀបធៀបស្ថានភាពឆ្នាំ១៩៧០ និង១៩៧៣ ហើយលោកបានប្រៀបធៀបពីស្ថានភាព អំពីភាពខុសគ្នាអំពីឆ្នាំ១៩៧៣ ដល់ ១៩៧៥ ផងដែរ។ សូមលោកពន្យល់តុលាការ?

**ឆ៖** ស្ថានភាពគឺថាវាមានភាពតានតឹងណាស់ក្នុងឆ្នាំ១៩៧៥ ហើយខ្ញុំខ្លួនឯងហ្នឹងយល់ឃើញថាមិនអាចយកឈ្នះបានទេ អ្វីៗនៅទីនេះគឺទោះបីជាសហរដ្ឋអាមេរិក ដូចជាសង្គ្រាមអាមេរិកនៅវៀត-ណាម គម្បីតែដោះស្រាយ។ ប៉ុន្តែនៅទីនេះគឺសង្គ្រាមចេះតែបន្ត ហើយខ្ញុំមិនឃើញមានឱកាសថា របបលន់ នល់ អាចថានឹង -- ព្រោះថា វាមិនអាចដូចសង្គ្រាមចប់នៅអាមេរិក នៅវៀតណាមនោះទេ គឺវាអាចនឹងខុសពីហ្នឹង។

**ស៖** តើលោកបានដឹងដែរឬទេ ថាតើជនភៀសខ្លួននៅភ្នំពេញទទួលបានអាហារយ៉ាងដូចម្តេចដែរ តាំងពីឆ្នាំ១៩៧៣ រហូតមកដល់ឆ្នាំ១៩៧៥នោះ?

[០៩:២៦:១៥]

**ឆ៖** ចំពោះអ្នកដែលមិននៅក្នុងប្រព័ន្ធជនភៀសខ្លួនទេ មិនបានទទួលស្បៀងអាហារទៀងទាត់ទេ គឺគេដើររកអាហារដោយខ្លួនឯង គេអាចធ្វើអ្វីតាមតែលទ្ធភាពគេអាចធ្វើ។ នៅក្នុងពេលដែលខ្ញុំនៅទីនេះ គឺថាមានឃ្លាំងផ្ទុកស្បៀងច្រើននៅតាមបណ្ដោយមាត់ទន្លេ ហើយស្បៀងអាហារ ហើយនិងមានគ្រាប់រំសេវ គឺថាដឹកមកជាមួយស្បៀងអាហាររាប់ពាន់តោនមកតាមផ្លូវទឹក ហើយគឺយើងបានដាក់មកក្នុងឃ្លាំង ហើយក៏បានយកមនុស្សធ្វើការនៅក្នុងឃ្លាំងក្នុងការចែកស្បៀងអាហារ។ ប៉ុន្តែមានជនភៀសខ្លួនខ្លះក៏បានលួចស្បៀងអាហារនោះខ្លះដែរ។ អ្នកខ្លះគេពាក់អាវដៃវែង ដើម្បីគេដាក់ ហើយគេដាក់ទុយោដែកស៊កទៅចូលក្នុងបាវអង្ករដែលគេលី ហើយគេបង្ហូរចូលមកក្នុងដៃអាវរបស់គេ។ ហើយខ្ញុំបានឃើញអ្នកដែលធ្វើការលើអង្ករហ្នឹង គឺថាឃើញមាឌធំ ហើយឃើញថាអាចលួចអង្ករច្រកទៅក្នុងអាវហ្នឹង ឃើញកំប៉ោង។ អ៊ីចឹងគឺថា អាចនឹងបានស្បៀងហ្នឹងយកទៅចិញ្ចឹមក្រុមគ្រួសារ។ គឺថា អ្វីៗដែលអាចថា គេហូបបាន គឺជនភៀសខ្លួនហ្នឹងប្រមូលយកទៅហូបបានទាំងអស់ គឺគេខ្វះខាត។ ហើយកងទ័ពហើយទាហាន គឺថាអាចនឹងមានរបបនឹងផ្គត់ផ្គង់គ្រួសារ។ ដូចដែលខ្ញុំជម្រាប គឺថាបើយើងជាគ្រួសារមួយ ក្នុងគ្រួសារយើងមិនមានអ្វីហូបទេនោះ គឺថាពួកគាត់មិនមានៗអ្វីហូប ពេលខ្លះយើងត្រូវទៅជនភៀសខ្លួនទៅជំរំទីនោះ។ ហើយគេបានទទួលការុង ឬក៏បាវអង្ករ -- អង្ករមួយបាវ។ ហើយចំពោះអ្នកដែលនៅក្រៅវិញ គឺគេពិបាក។ រីឯ -- កាលនោះគឺមិនមានត្រីស្រស់ទេ គេចែកតែត្រីប្រឡាក់សម្រាប់ជនភៀសខ្លួននោះឯង ហើយនិងអ្នកធ្វើការផងដែរ។

[០៩:២៨:៣២]

**ស៖** នៅពេលដែលលោករ៉ុកហ្វូនៅភ្នំពេញ ថាតើតម្លៃស្បៀងអាហារវាមានការកែប្រែអ្វីខ្លះនោះទេ?

**ឆ៖** តម្លៃចេះតែឡើងជារៀងរាល់ថ្ងៃ។ ប៉ុន្តែខ្ញុំមិនអាចផ្ដល់ការវាយតម្លៃថាវាប៉ុន្មានភាគរយអតិផរណាប៉ុន្មានទេ ប៉ុន្តែស្បៀងអាហារពិបាករកណាស់។ បើលោកមានលុយ លោកអាចទិញស្បៀងអាហារបាន។ ប៉ុន្តែវាមានភាពខុសគ្នា មានខ្មែរជាច្រើន ដែលយកស្បៀងអាហារមកភ្នំពេញ ប៉ុន្តែហើយគេអាចយកមកពីខេត្តនានាបាន ប៉ុន្តែការដឹកជញ្ជូននោះគឺវាមានការលំបាក។ ភ្នំពេញគឺពឹងផ្អែកទៅលើប្រភពខាងក្រៅសម្រាប់អាហារហ្នឹង។ តម្លៃស្បៀងអាហារ ខ្ញុំមិនអាចនឹងឆ្លើយលោកបានទេ ពីព្រោះថាខ្ញុំមិនបានទិញអាហារនៅតាមផ្សារទេអង្កាល់នោះ។

**ស៖** លោក រ៉ុកហ្វូ ម្សិលមិញនោះលោករៀបរាប់អំពីចំនួនជនភៀសខ្លួននៅភ្នំពេញ លោកបាន

និយាយថា ខ្ញុំសង្ខេបនេះ បើខ្ញុំខុសគឺថាកែតម្រូវថា លោកនិយាយថា ដោយហេតុថាមានជនភៀសខ្លួនច្រើនពេកនៅភ្នំពេញនោះ មិនមានអ្វីភ្ញាក់ផ្អើលទេនៅពេលដែលចប់សង្គ្រាមទៅ គេទៅកន្លែងណាដែលគេមកនេះ។ តើលោកអាចបំភ្លឺតុលាការអ្វីបន្ថែមទៀតទេអំពីបញ្ហានេះ ដែលលោកបញ្ជាក់ម្សិលមិញនោះ?

**ឆ៖** នៅក្នុង២-៣សប្តាហ៍មុនពេលថ្ងៃទី១៧ ខែមេសា នោះគឺថាយើងមិនឃើញថា សង្គ្រាមជិតចប់ហើយ គឺថានៅពេលដែលសង្គ្រាមចប់គឺគេត្រឡប់ទៅកន្លែងណាវិញដែលគេមកនោះឯង។ ពួកគេមិនចាប់អារម្មណ៍ចង់នៅភ្នំពេញទេ ពីព្រោះគេជៀសពីជនបទមកទីនេះ គឺដើម្បីឲ្យបានសុវត្ថិភាព។ អ៊ីចឹងកាលណាសង្គ្រាមចប់ គេនឹងត្រឡប់ទៅវិញ។

[០៩:៣០:៤៥]

**ស៖** ប៉ុន្តែតើលោកដឹងដោយរបៀបណា ថាតើលោកបានជួបសួរជាមួយជនភៀសខ្លួន ដើម្បីសួរគេថា គេចង់ចង់ទៅស្រុកវិញ ឬមួយក៏យ៉ាងដូចម្តេចដែរ?

**ឆ៖** ខ្ញុំអត់បានសួរជនភៀសខ្លួនអំពីការចង់ត្រឡប់ទៅស្រុកវិញនោះទេ។ ប៉ុន្តែអ្នកថតរូប និងអ្នកសារព័ត៌មានកម្ពុជា ដែលបានចុះទៅតាមទីកន្លែងគឺបានប្រាប់មកខ្ញុំតាមរយៈការបកប្រែ។ គឺថាជនភៀសខ្លួនបានប្រាប់ទៅអ្នកសារព័ត៌មានជាតិថា នៅពេលដែលសង្គ្រាមចប់គេត្រឡប់ទៅស្រុកវិញហើយ។ ខ្ញុំមិនអាចធានាថា ចំពោះជនភៀសខ្លួនប្រហែល២លាននាក់ហ្នឹង គាត់ចង់ត្រឡប់ទាំងអស់នោះទេ ប៉ុន្តែខ្ញុំអាចនិយាយថា ភាគច្រើន។ ដូច្នេះខ្ញុំមិនអាចបញ្ជាក់ឲ្យបានច្បាស់អំពីការនិយាយ ឬក៏ពាក្យសម្តីរបស់ជនភៀសខ្លួនណាម្នាក់នោះទេ ប៉ុន្តែខ្ញុំគិតថាវាជាការត្រឹមត្រូវ។ នៅថ្ងៃ១៧ មេសា ៧៥ គឺថាប្រជាជនមិនមានការជំទាស់ ឬក៏មិនមានការតវ៉ាខ្លាំងនៅពេលដែលគេជម្លៀសចេញពីភ្នំពេញនោះឡើយ។ គឺថាមានការជំទាស់ខ្លាំងក្លាតែបន្តិចបន្តួចប៉ុណ្ណោះ។ ចំពោះអ្នកដែលភៀសខ្លួនមកភ្នំពេញ មកតាមភាគខាងជើង គាត់ជំទាស់នៅពេលដែលគេបញ្ជូនគាត់ទៅទិសផ្សេង។

[០៩:៣២:១២]

ដូច្នេះអាហ្នឹងគឺគាត់ជំទាស់ដោយសារគេបញ្ជូនគាត់ទៅកន្លែងខុសពីមុន។ នៅថ្ងៃដំបូងនៃការរំដោះទីក្រុងភ្នំពេញហ្នឹង គឺថាប្រជាជនជឿជាក់ថា គាត់អាចត្រឡប់ទៅស្រុកគាត់វិញបាន។ ហើយពួកគាត់ក៏មិនដឹងច្បាស់ថាយ៉ាងម៉េចដែរ ព្រោះហើយម្យ៉ាងទៀត គាត់ជឿថាអាមេរិកនឹងទម្លាក់គ្រាប់បែកនៅភ្នំពេញ។ ដូច្នេះហើយគាត់ចាកចេញ។ ប្រជាជនភាគច្រើន គាត់រត់មកភ្នំពេញដើម្បីគេចពីគ្រោះថ្នាក់

គេចពីការទម្លាក់គ្រាប់បែក។ ដូច្នេះប្រសិនបើគេនិយាយថា នឹងមានការទម្លាក់គ្រាប់បែក គឺពួកគេងាយនឹងជឿមែនទែន។

**ស៖** ប្រសិនបើលោកនិយាយថា មិនមានការតវ៉ាខ្លាំងក្លានៅពេលដែលគេឲ្យចាកចេញពីទីក្រុងភ្នំពេញឆ្នាំ៧៥ហ្នឹង តើលោកអាចពន្យល់ ឬក៏បង្ហាញបានឬទេ តើផ្អែកទៅលើអ្វី ឬក៏ពឹងផ្អែកទៅលើមូលដ្ឋានអ្វីដែលលោកបានិយាយបែបនេះ?

[០៩:៣៣:១៦]

**ឆ៖** ខ្ញុំមិនឃើញមានការតវ៉ាជំទាស់អ្វីឡើយ នៅពេលដែលខ្ញុំមានវត្តមាននៅទីនោះ គឺខ្ញុំឃើញមានការទម្លាក់គ្រាប់បែកច្រើន ប៉ុន្តែដូចជាមិនមានការរឹងទទឹងអ្វីនោះឡើយ។ ពេលខ្លះយើងឮស្នូរសំឡេង ប៉ុន្តែយើងមិនដឹងថាមានអ្វីកើតឡើង។ វាមានកន្លែងមួយចំនួននៅមានការវាយប្រហារគ្នារប៉េះរប៉ោះ គឺប្រហែលជាមួយសប្តាហ៍ក្រោយថ្ងៃ១៧ មេសានោះ គឺនៅតែមានការរើ ប៉ុន្តែតិចតួច។ គឺនៅទីនោះគឺមានកងកម្លាំងទ័ពអាកាសកម្ពុជាតវ៉ា វាយប្រយុទ្ធជាមួយពួកទាហានខ្មែរក្រហមជាដើម គឺនៅមានការវាយគ្នាបន្តិចបន្តួច ហើយមានការផ្ទោង ឬក៏ការបាញ់ផ្តក់បន្តិចបន្តួចដែរ។ គឺថាការបាញ់ប្រហារគ្នានេះកើតឡើងប្រហែលមួយសប្តាហ៍ក្រោយ ថ្ងៃ១៧ មេសា។ គឺថានៅក្នុងរោងចក្រកែវក៏អាចមានការតវ៉ា មានការប៉ះបោរនេះដែរ។

**ស៖** តើលោកចង់និយាយថា លោកមិនបានឃើញការរឹងទទឹងតវ៉ា ពីប្រជាជនស៊ីវិលនៅក្នុងថ្ងៃ១៧ មេសា តើមែនទេ?

**ឆ៖** ខ្មែរក្រហមគាត់មានកាំភ្លើងអាកា គាត់មានអំណាច តើជនស៊ីវិលធ្វើអីបាន។ ប្រសិនបើទាហានមកបង្ខំគ្រួសារលោកឲ្យចាកចេញ តើលោកមានអីធ្វើ ធ្វើអីកើត?

[០៩:៣៥:០០]

**ស៖** លោក រ៉ុកូហ្វ តើខ្ញុំអាចនិយាយបានដែរឬទេ នៅពេលដែលលោកឃើញទាហានខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅម៉ោងប្រាំបី ថ្ងៃ១៧ មេសា រហូតដល់ពេលលោកចូលស្ថានទូត ថាតើលោកមានបានជួបប្រទះ -- តើលោកមានធ្លាប់ឃើញទាហានដែរឬទេ? លោកមានធ្លាប់ជួបពួកទាហានដែរឬទេនៅពេលនោះ?

**ឆ៖** ខ្ញុំជួបជាមួយនឹងទាហានខ្មែរក្រហម ប៉ុន្តែមិនមែនជាការជួបដោយផ្ទាល់ខ្លួននោះទេ។ គឺយើងគ្រាន់តែឃើញទាហានដែលជិះតាមឡានចូលមកតាមផ្លូវ តាមទិសដែលខ្ញុំចង់ទៅដែរនោះ។ ហើយ

ខ្ញុំបានជួបជាមួយនឹងទាហានដែរ ប៉ុន្តែទាហានឋានៈទាប ហើយបានជួបតាមផ្លូវនោះទេ។ យើងជួបប្រហែលជា២ម៉ោង។ ប៉ុន្តែប្រសិនបើនិយាយអំពីការប្រាស្រ័យទាក់ទងជាលក្ខណៈបុគ្គលជាមួយទាហានខ្មែរក្រហម គឺខ្ញុំមិនដែលមាននោះទេ។ ខ្ញុំមិនចេះនិយាយភាសាខ្មែរច្បាស់លាស់ ហើយខ្ញុំមិនមែនជាអ្នករាយការណ៍ មិនមែនជាអ្នកយកព័ត៌មាន ដូច្នេះខ្ញុំមិនបានធ្វើការប្រាស្រ័យទាក់ទងជាលក្ខណៈបុគ្គលជាមួយពួកខ្មែរក្រហមនោះទេ។ អ្វីដែលខ្ញុំបានឃើញ គឺគ្រាន់តែឃើញទាហានជិះឡានតាមផ្លូវនរោត្តម ហើយបើកទៅមុខប៉ុណ្ណោះ។ ហើយខ្ញុំបានជិះជាមួយពួកទាហានខ្មែរក្រហមនោះដែរ ខ្ញុំអាចបានជួបជាមួយទាហានខ្មែក្រហមដែរដើរតាមផ្លូវ ខ្ញុំអាចដឹងពីអារម្មណ៍ ដឹងពីលក្ខណៈរបស់ពួកគេ។ បន្ទាប់មកគឺខ្ញុំបានប្តូរទីតាំងដើរៗទៅខាងស្ថានទូតអាមេរិកវិញ គឺខ្ញុំមិនដើរតាមពួកទាហានខ្មែរក្រហមនោះឡើយ។ ដូច្នេះអ្វីដែលខ្ញុំឃើញ គឺគ្រាន់តែឃើញថាទាហានខ្មែរក្រហមដើរជាមួយគ្នា ចែកចំណីអាហារឲ្យគ្នាទៅវិញទៅមក អ្នកខ្លះគាត់ដើរពាក់ស្បែកជើង អ្នកខ្លះគាត់ជិះឡាន ប៉ុន្តែខ្ញុំមិនបាននិយាយអ្វីឲ្យបានច្រើន គ្រាន់តែឃើញទាហានខ្មែរក្រហមខ្លះគាត់សើចដាក់ខ្ញុំ ហើយអ្នកខ្លះគាត់ចេះនិយាយអង់គ្លេសបន្តិចបន្តួច គាត់សួរខ្ញុំ តើអ្នកឯកអាមេរិកាំងទេ? ហើយខ្ញុំក៏ថាអាមេរិកាំងបែបនេះឯង។ នេះគឺជាអ្វីដែលខ្ញុំបានជួប បានប្រាស្រ័យ បាននិយាយដោយផ្ទាល់ជាមួយទាហានខ្មែរក្រហម គឺតែប៉ុណ្ណោះ។ ប៉ុន្តែនិយាយឲ្យសង្ខេបទៅ គឺខ្ញុំមិនមានការទាក់ទងអ្វីដោយផ្ទាល់ ជាលក្ខណៈបុគ្គលជាមួយទាហានខ្មែរក្រហមនោះទេ។ ខ្ញុំបានត្រឹមតែថតរូបប៉ុណ្ណោះឯង។ អត់មានអ្នកណាសួរខ្ញុំ អត់មានអ្នកណានិយាយជាមួយខ្ញុំទេ។

[០៩:៣៨:០០]

ហើយចំពោះហេតុការណ៍នៅមន្ទីរពេទ្យព្រះកេតុមាលានុំង គឺក្រោយមកត្រូវបានគេយកទៅស្ពានជ្រោយចង្វា។ ទោះបីគេយកខ្ញុំទៅដាក់នោះក៏ដោយ ក៏គ្មានអ្នកណាសួរនាំ និយាយអ្វីខ្ញុំដែរ។ គឺថានៅពេលដែលគេយកទៅនុំង គឺ ឌិត ប្រន គាត់បានប្រាប់ថាយើងជាជនជាតិបាំរាំង ហើយក៏មិនមានអ្វីច្រើនបន្ថែមទៀតដែរ។ ហើយក៏មិនមានអ្នកណាសួរនាំថាបារាំង ឬក៏មិនបារាំងនោះដែរ។ ខ្ញុំសំណាងដែរនៅពេលនោះ។

**សៈ** លោកសាក្សីផ្អែកទៅលើបទពិសោធន៍របស់លោក តើលោកអាចរៀបរាប់បានដែរឬទេថាទាហានខ្មែរក្រហមគឺជាក្រុមតែមួយ ឬមួយក៏ជាក្រុមដែលមានលក្ខណៈច្រើនគ្នាផ្អែកទៅលើសម្លៀកបំពាក់ ឬក៏អាកប្បកិរិយា ឬក៏លក្ខណៈរបស់ទាហានខ្មែរក្រហមហ្នឹង តើវាជាក្រុមតែមួយ ឬក៏ក្រុមច្រើន?

[០៩:៣៩:០១]

**ឆ៖** ទាហានខ្មែរក្រហមមកពីតំបន់ផ្សេងៗគ្នា គឺមានលក្ខណៈខុសៗគ្នា ដូចជាអ្នកខ្លះគាត់មានកាំភ្លើងអាកាសឹងតែថា១០០ភាគរយ អ្នកខ្លះគាត់មានសម្លៀកបំពាក់ផ្សេង អាចថាសម្លៀកឯកសណ្ឋានមិនដូចគ្នា អ្នកខ្លះគាត់កាន់អឹមសីជាដើមទៅ។ នេះគឺវាមានលក្ខណៈខុសៗគ្នាបែបនេះដែរ។ ខ្ញុំសូមទោសចុះ ខ្ញុំហាក់ដូចជាភ្លេចអំពីបញ្ហានេះ។ ប៉ុន្តែអ្វីដែលយើងនិយាយបាន គឺខ្មែរក្រហមមានកាំភ្លើងមានគ្រាប់រំសេវច្រើន។ យើងឃើញមានគ្រាប់កាំភ្លើងអាកា ក៏ដូចជាអ៊ឹមសីជាដើម កាំភ្លើងដែលបានពីអាមេរិក គឺជាគ្រាប់រំសេវ និងកាំភ្លើងដែលទទួលបានពីខាងទាហាន លន់ នល់។ ហើយយើងដឹងហើយថាអាមេរិកគាត់ផ្តល់អាវុធគ្រាប់រំសេវដល់ទាហាន លន់ នល់។ ដូច្នេះអានេះគឺជាអ្វីដែលទាហានខ្មែរក្រហមបានទទួល។ ទាហានខ្លះគាត់មានឯកសណ្ឋានស្អាតបាត ហើយមើលទៅគឺថាគាត់មានប្រដាប់អាវុធគ្រប់គ្រាន់ ប៉ុន្តែអ្នកខ្លះទៀត គាត់ដូចជាមិនមានឯកសណ្ឋានស្អាតបាត ឬក៏មានអាវុធគ្រប់គ្រាន់នោះទេ។

**ស៖** ចុះអាកប្បកិរិយារបស់ក្រុមផ្សេងៗគ្នា តើលោកសង្កេតឃើញថាមានអាកប្បកិរិយាខុសៗគ្នាដែរឬទេ របស់ទាហានខ្មែរក្រហមនោះ?

[០៩:៤០:៤៦]

**ឆ៖** គឺថាគេមានសមាសភាពមួយរួមគ្នាគឺក្រុមមួយដែលមានគ្នាប្រហែលជា៦០០ នាក់មកជួបខាងទាហាន លន់ នល់ ហើយពួកគេស្នាក់នៅក្នុងវត្តមិនឆ្ងាយពីទីនេះប៉ុន្មានទេ។ នៅខាងលិចអង្គស្នួលនៅជិតផ្លូវជាតិ ហើយពួកទាហានខ្មែរក្រហមទាំងនោះចាត់ទុកថាខ្លួនឯងជាអ្នកស្នេហាជាតិ ជាអ្នករំដោះជាតិ ហើយជាអ្នកស្នេហាសីហនុនិយមជាដើម។ ហើយពួកនោះគេមិនជួបជាមួយរដ្ឋាភិបាលហើយមានពិធីបុណ្យ ហើយពួកគេបានចុះចូលហើយប្រគល់អាវុធទៅឲ្យទាហាន លន់ នល់ ប៉ុន្តែនេះគឺជាអ្វីមួយដែលប្លែកពីគេ។ ហើយគេរក្សាទុកពួកទាហានទាំងអស់នេះជាមួយកង ហើយគេមិនដែលបញ្ជូនត្រឡប់ទៅវិញនោះឡើយ។ នេះគឺជាអ្វីដែលខ្ញុំដឹង គឺជាក្រុមដែលផ្តាច់ខ្លួនចូលទៅជាមួយទាហាន លន់ នល់។ ហើយគេបានទទួលនូវការព្រមព្រៀងមួយពីទាហាន លន់ នល់។ ពួកនោះវាមិនដូចជាទាហានខ្មែរក្រហមផ្សេងៗទេ គេថាខ្លួនគេនោះជាទាហានខ្មែររំដោះ។ ប៉ុន្តែអ្វីដែលខ្ញុំនិយាយហ្នឹងគឺថាវាគួរឲ្យចាប់អារម្មណ៍ ដែលក្រោយមកគឺយើងមានការប្រាស្រ័យទាក់ទងជាមួយពួកនេះ ទោះបីថាពួកគេប្តូរ ឬផ្តាច់ខ្លួនមកក៏គេនៅតែរក្សាអាវុធយុទ្ធភណ្ឌដដែល។

**ស៖** តើលោកដឹងដែរឬទេ ថាពួកខ្មែរក្រហម -- ផ្ដាច់ខ្លួនខ្មែរក្រហមហ្នឹងវាមានលក្ខណៈខុសគ្នាយ៉ាងម៉េចដែរជាមួយនឹង -- តើពួកផ្នែកខាងជើង ផ្នែកខាងត្បូងនោះ ខុសគ្នាយ៉ាងម៉េចដែររបស់ទាហានខ្មែរក្រហមនោះ?

**ឆ៖** ប្រសិនបើមានការខុសគ្នាក៏ខ្ញុំមិនដឹងដែរ នៅពេលនោះខ្ញុំមិនដឹងថាវាខុសគ្នាបែបណានោះទេ។

[០៩:៤៣:១៧]

**ស៖** លោក រ៉ូក្វូ តើទាហានខ្មែរក្រហម មានទាហានខ្មែរក្រហមណាដែលថាមិនធ្លាប់ស្គាល់ទីក្រុងភ្នំពេញ ឬក៏ធ្លាប់មកទីក្រុងដែរឬទេ? មិនដែលដឹងអំពីចរាចរណ៍នៅទីក្រុងដែរឬទេ?

**ឆ៖** ខ្ញុំមានរូបថតជាច្រើនទាក់ទងទៅនឹងទាហានខ្មែរក្រហមដែលមើលទៅលើអគារ ហើយគាត់សសើរអំពីអគារនៅតាមផ្លូវមុនីវង្ស ផ្លូវនរោត្តម ហើយនៅពេលមានឡានដឹកទឹកក្រូចយកមកទម្លាក់ឲ្យពួកទាហានខ្មែរក្រហមមួយចំនួនហ្នឹងគឺថា ខ្មែរក្រហមសុំបារី ហើយគេប្រើសញ្ញាមួយ ដែលគេប្រើជាទូទៅគេធ្វើដៃដូចដែលខ្ញុំធ្វើដូច្នេះ គឺគេសុំបារី។ នៅពេលព្រឹកគឺល្អ អ្វីៗគឺដូចរីករាយ ប៉ុន្តែនៅពេលដែលទាហានខ្មែរក្រហមដែលមានលក្ខណៈតឹងរ៉ឹងមកពីខាងត្បូងគឺហាក់ដូចជាមានការប្រែប្រួល។ ពួកនោះគឺគេមានកាំភ្លើងធំ ហើយគេបាញ់កាំភ្លើងច្រើននៅតាមផ្លូវមុនីវង្ស។ ខ្ញុំមិនភ្ញាក់ផ្អើលទេនៅពេលដែលខ្មែរក្រហមធ្វើបែបនេះ។ ព្រោះមានការវាយប្រហារខ្លាំងជាមួយទាហាន លន់ នល់ ដើម្បីការពារកុំឲ្យទាហានលន់ នល់ ឆ្លងស្ពានមកចូលទីក្រុងភ្នំពេញ។

**ស៖** តើទាហានខ្មែរក្រហមហ្នឹង មានអ្នកខ្លះមើលទៅតឹងតែង ឬក៏ម៉ឺងម៉ាត់ជាងអ្នកដទៃទៀតដែរឬទេក្នុងចំណោមទាហានខ្មែរក្រហមដូចគ្នានោះ?

**ឆ៖** បាទ។ អ្នកដែលតឹងតែងហ្នឹងច្រើនតែពួកអ្នកចាស់ៗ ចំណែកអ្នកដទៃមិនសូវអីប៉ុន្មានទេ។ យើងមើលទៅឃើញការគ្រប់គ្រងល្អ មិនមានការ -- មិនមានឋានៈអ្វីឲ្យខុសគ្នាខ្លាំងក្លានោះទេ។ ប៉ុន្តែពួកគេដឹងថាអ្នកណាទទួលខុសត្រូវ អ្នកណាជាមេជាកោយ។ ពួកគេបញ្ជាដោយផ្ទាល់មាត់ ហើយគេអនុវត្ត អានេះគឺអ្វីដែលខ្ញុំបានឃើញ។ ដូចដែលខ្ញុំបានបញ្ជាក់កាលពីម្សិលមិញ គ្រីស្តូហ្វ ម៉ារី ប្រូដាដែលជាអ្នកថតរូបឲ្យសារព័ត៌មាន អា.ប៉េ គឺជាខ្សែភាពយន្តដែលបង្ហាញពីមន្ត្រីខ្មែរក្រហម។ គឺលោកអាចឃើញរូបថតទាំងអស់នេះបាន។ រូបភាពនេះបង្ហាញថា មេខ្មែរក្រហមហ្នឹងបញ្ជាកូនចៅគាត់នៅម្តុំផ្សារថ្មី ហើយបញ្ជាឲ្យចេញពីហាង ហើយបញ្ឈប់ការលួចអីវ៉ាន់នៅតាមហាង។ ខ្ញុំអាចនិយាយថាវាជា

ការលួចប្លន់នៅតាមហាង ប៉ុន្តែអ្វីដែលគេចង់បានខ្លាំង គឺបារីនោះទេ។ ខ្ញុំគិតថា វាស្តាប់ទៅចម្លែកប៉ុន្តែ វាជាការពិត ព្រោះថាពួកខ្មែរក្រហមភាគច្រើនគឺជក់បារី។

[០៩:៤៦:៥៣]

**ស៖** លោក រ៉ុកូហ្វ តើលោកចាំដែរឬទេ ថាមានទំនាក់ទំនងរវាងតំបន់នានានៅក្នុងទីក្រុងដែលលោកអាចគិតថា តំបន់មួយមានអាកប្បកិរិយាមួយខុសៗគ្នាដែរឬទេ?

**ឆ៖** សូមអភ័យទោស ខ្ញុំមិនច្បាស់អំពីសំណួររបស់លោក។ តើលោកចង់និយាយបែបណាដែរទាក់ទងនឹងអាកប្បកិរិយា?

**ស៖** ខ្ញុំចង់និយាយថា មានទាហានខ្លះគាត់តឹងតែង ខ្លះគាត់ធូររលុងដែរឬទេ? ថាតើលោកអាចចាំដែរឬទេ ថាតំបន់មួយហ្នឹង គឺទាហានមានលក្ខណៈម៉ឺងម៉ាត់ ចំណែកតំបន់មួយទៀតទាហានហ្នឹងហាក់ដូចជាមិនសូវជាម៉ឺងម៉ាត់ខ្លាំងដែរឬទេ? តើលោកសង្កេតឃើញបែបនេះដែរឬទេ?

**ឆ៖** ទាក់ទងទៅនឹងអាកប្បកិរិយាដែលខ្ញុំបានសង្កេតឃើញ គឺហាក់ដូចជាមិនល្អសោះ អាកប្បកិរិយាមិនល្អ។ ជាពិសេសក្រុមដែលដើរទៅទិសខាងជើង ទៅវិមានឯករាជ្យ ព្រោះថាភាគច្រើននៃទាហានហ្នឹងវាហាក់ដូចជាកូនសិស្សនៅក្មេងៗ ហើយពួកគេនិយាយមកខ្ញុំថា អ្នកឯងអាមេរិកកាំងអ្វី អ្នកឯងជនជាតិអាមេរិកាំង គឺគេសួរខ្ញុំរហូតអ៊ីចឹង។ ពួកគេមានអារម្មណ៍ មានលក្ខណៈដូចជាអស់កម្លាំង ហត់នឿយជាខ្លាំង។ ទាហានខ្មែរក្រហមមួយចំនួនដែលគេចូលមកទីក្រុងភ្នំពេញ មើលទៅដូចជាមិនអស់កម្លាំង ឬក៏មិនហត់នឿយ ហាក់ដូចជាពួកគេមកពីក្រុមផ្សេង ឬក៏មកពីកន្លែងផ្សេង។

[០៩:៤៨:៣៣]

ដូចដែលខ្ញុំបានបញ្ជាក់កាលពីម្សិលមិញអ៊ីចឹង គឺពួកខ្មែរក្រហមដែលស្លៀកពាក់ស្អាតបាត ដែលជាលក្ខណៈក្លែងក្លាយមួយចំនួន ក៏មានលក្ខណៈក្លែងក្លាយដែរ គឺពួកទាហានខ្មែរក្រហមក្លែងក្លាយនោះឯង។ គឺជាពួកដែលនៅក្រសួងព័ត៌មាន ដែលមិនមានលក្ខណៈអ្វីបង្ហាញថាជាទាហានខ្មែរក្រហមនោះ។ ចំពោះទាហានខ្មែរក្រហមដែលជិះឡានចូលមកទីក្រុងភ្នំពេញ បើកកាត់ស្ថានទូតបារាំងដើម្បីទៅយកពួកកម្មាភិបាលយកមកចូលទីក្រុងហ្នឹង គឺពួកហ្នឹងគឺហាក់ដូចជាមានអារម្មណ៍រីករាយ មិនមានបញ្ហាអ្វីនោះទេ គឺគេមានកាំភ្លើង គេមានមីក្រូដើម្បីប្រកាសពីព័ត៌មាននានា។ នេះគឺជាអ្វីដែលប្រជាជនចង់ឮនៅពេលដែលគេប្រកាសព័ត៌មាន។ ខ្ញុំមានរូបថត ថតប្រជាជននៅមុខព្រះវិហារ គឺអតីតព្រះវិហារសាសនាគ្រិស្តដែលនៅក្បែរសណ្ឋាគារឡឺរ៉ូយ៉ាល់នោះ។ ហើយប្រជាជនញញឹមស្រស់ស្រាយទៅកាន់កម្មាភិបាល

ហើយឡាននោះបានបើកមកខាងក្រសួងព័ត៌មានវិញ។ ពួកទាហានមានទឹកមុខស្រស់ស្រាយ ហើយខ្ញុំបានថតរូបទាំងអស់នេះ គឺជារូបភាពដែលកើតឡើងប៉ុន្មានម៉ោងដំបូងនៃការចូលមកដល់ទីក្រុងភ្នំពេញ។

**ស៖** ខ្ញុំមានសំណួរមួយទៀតលោក រ៉ុក្ហ្វ តើលោកស្គាល់មនុស្សម្នាក់ឈ្មោះ ដាកក្លេស សាបភឺ (Douglas Sapper) ដែរឬទេ?

**ឆ៖** បាទ ខ្ញុំស្គាល់។

**ស៖** តើលោកអាចប្រាប់បានទេថា ដាកក្លេស សាបភឺ ហ្នឹងគឺជាអ្នកណា?

**ឆ៖** គាត់ជាជនជាតិអាមេរិក គឺអតីតទាហានអាមេរិក គាត់នៅកងទ័ពអាកាសអាមេរិក។ គាត់ជាប្រធានសន្តិសុខអាកាសចរណ៍ ហើយគាត់នៅក្នុងស្ថានទូតបារាំងជាមួយពួកយើងទាំងអស់គ្នាដែរ។ គាត់ចង់ចេញទៅក្រៅ ប៉ុន្តែគាត់ជាប់នៅក្នុងស្ថានទូតជាមួយយើង។

[០៩:៥១:២០]

ខ្ញុំមិនស្គាល់គាត់ឲ្យច្បាស់នោះទេ ប៉ុន្តែគ្រាន់ខ្ញុំដឹងថា ខ្ញុំស្គាល់លោក ដាកក្លេស សាបភឺ មុនពេលដែលយើងមកជាប់ស្ថានទូតបារាំងនេះ។ ប៉ុន្តែមុនពេលដែលគាត់មកធ្វើការនៅអាកាសចរណ៍ហ្នឹង ខ្ញុំមិនដឹងថា គាត់ធ្វើអ្វីនោះទេ។ ខ្ញុំមិនស្គាល់គាត់ច្បាស់នោះទេ។

**ស៖** តើនៅពេលនុ៎ងលោកមានបានពិភាក្សាជាមួយលោក ដាកក្លេស សាបភឺ ដែលអំពីទាហានខ្មែរក្រហមដែរឬទេ នៅពេលដែលលោកនៅក្នុងស្ថានទូតនោះ?

**ឆ៖** ខ្ញុំដូចជាមិនបានពិភាក្សាអ្វីជាមួយក្នុង -- ជាមួយគាត់អំពីទាហានខ្មែរក្រហមនៅក្នុងស្ថានទូតនោះទេ។ ប្រហែលជាយើងបានពិភាក្សា ឬមួយក៏អាចមិនពិភាក្សា ក៏ប៉ុន្តែខ្ញុំចាំថា ខ្ញុំមិនបានពិភាក្សាអំពីបញ្ហាទាហានខ្មែរក្រហមទេ អាចថានិយាយអំពីរឿងអាកាសចរណ៍អ្វីនោះអាចថាមាន។

[០៩:៥២:៥០]

**ស៖** ខ្ញុំនឹងលើកយកប្រធានបទចុងក្រោយមួយទៀតមកពិភាក្សា ហើយសំណួររបស់ខ្ញុំគឺថា តើលោកធ្លាប់ឃើញខ្សែភាពយន្តដែលហៅថា “វាលពិឃាដ” ដែលដឹកនាំដោយ រ៉ូន ចូស (Roland Joffé) ដែរឬទេ?

**ឆ៖** គេតែងតែសួរខ្ញុំអំពីបញ្ហានេះ។ នៅក្នុងឆ្នាំ៨៩ ដែលខ្ញុំមកទីនេះ គេតែងសួរតើលោកធ្លាប់មើលកុនវាលពិឃាដដែរឬទេ? សូម្បីតែពេលខ្ញុំដើរតាមផ្លូវ ឬជិះរ៉ឺម៉កនោះក៏គេសួរ ធ្លាប់ឃើញកុនរឿងវាលពិឃាដដែរឬទេ? ខ្ញុំបានចូលរួមជាមួយខ្សែភាពយន្តនោះដែរ ប៉ុន្តែខ្ញុំមិន -- តែផ្នែកនោះមិនបាន

បង្ហាញជាសាធារណៈនោះទេ។ ខ្ញុំបានចូលរួមការងារមួយចំនួនដែរ ហើយខ្ញុំបានផ្តល់នូវព័ត៌មាន ក៏ដូចជាការពិតមួយចំនួនដើម្បីថតនៅក្នុងខ្សែភាពយន្តនោះដែរ។ ព្រោះថាខ្សែភាពយន្តនេះ និយាយអំពីគ្រោះមហន្តរាយ ឬក៏អំពីសោកនាដកម្មដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា ហើយយើងត្រូវយកទៅបង្ហាញជាលក្ខណៈអន្តរជាតិ។ ព្រោះថាអ្វីដែលនិយាយ គឺជាសង្គ្រាមកម្ពុជា មិនមែនសង្គ្រាមវៀតណាមនោះឡើយ គឺវាជារឿងផ្សេងពីរខុសពីគ្នា។ គឺថាវាអាចមានបញ្ហាខុសឆ្គង ឬក៏មិនមាន -- វាមានកំហុសតិចតួចដោយសារតែគេលើកយកតួអង្គមកបង្ហាញខុសៗគ្នា ប៉ុន្តែយ៉ាងក៏ដោយខ្ញុំអាចនិយាយថា វាជាកុនល្អ។

[០៩:៥៤:២៧]

**ស៖** មូលហេតុដែលខ្ញុំសួរលោកអំពីទាំងអស់នេះ ព្រោះថាកាលពីសប្តាហ៍មុនខ្ញុំមើលកុនហ្នឹង ហើយឃើញថា អ្វីដែលលោកផ្តល់សក្ខីកម្មថ្ងៃនេះ និងកាលពីម្សិលមិញ គឺមានបង្ហាញនៅក្នុងខ្សែភាពយន្តនោះដែរ។ ដូច្នេះខ្ញុំគ្រាន់តែចង់ដឹងថា តើអ្នកដឹកនាំរឿងហ្នឹងគាត់មានអ្វី ព័ត៌មានអ្វីខ្លះពីលោកដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទានឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:៥៥:០៤]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចាំបាច់ត្រូវតែជំទាស់ទៅនឹងការលើកឡើងអំពីខ្សែភាពយន្ត។ ព្រោះថា ខ្សែភាពយន្តរឿងវាលពិឃាដនេះមិនមែនជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះឡើយ។ អង្គជំនុំជម្រះមិនមែនមានតួនាទីដើម្បីវាយតម្លៃអំពីខ្សែភាពយន្ត ដែលជាលក្ខណៈជាសិល្បៈ ជាល្ខោននោះឡើយ។ គឺយើងពិភាក្សាអំពីអង្គហេតុដែលបានកើតឡើង ជាការពិតដែលបានកើតឡើង។ ដូច្នេះ ខ្ញុំមិនយល់ឃើញថាមានភាពចាំបាច់ក្នុងការលើកយកខ្សែភាពយន្ត ដើម្បីមកធ្វើការប្រៀបធៀបជាមួយហេតុការណ៍ដែលបានកើតឡើងពិតប្រាកដនោះឡើយ។ ព្រោះមួយជាខ្សែភាពយន្ត មួយជាការពិត។ សូមអរគុណលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមដកសំណួរខ្ញុំចេញមកវិញបើដូច្នេះ។

សូមអរគុណលោករ៉ុក្កូហ្វដែលបានឆ្លើយនូវសំណួររបស់ខ្ញុំ។ សូមអរគុណ។

*(សម្រាករយៈពេលខ្លី)*

[០៩:៥៦:១២]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ! សូមគោរពលោកប្រធាន! ជម្រាបសួរលោក រ៉ុក្កូហ្វ។ ខ្ញុំឈ្មោះ សុន អរុណ។ ខ្ញុំក្រុមមេធាវីការពារជាតិរបស់លោកនួន ជា។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំមានសំណួរតិចទេ តែបីសំណួរទេ។ ទី១ គឺថា លោក រ៉ុក្កូហ្វ ជាអ្នកថតរូប លោកមិនទាន់បានបញ្ជាក់តាំងពីដើមមកថា ថតរូប -- ជាអ្នកថតរូបឯកជន ឬក៏អ្នកថតរូបឲ្យទៅកាសែត ឬក៏រូបភាពយន្តណាសូមលោកបញ្ជាក់ឲ្យច្បាស់?

**លោក អាល់ រ៉ុក្កូហ្វ៖**

**ឆ៖** ២ឆ្នាំដែលខ្ញុំធ្វើការនៅក្នុងប្រទេសកម្ពុជាជាអ្នកថតរូប គឺខ្ញុំមិនមានជាប់កិច្ចសន្យាជាមួយក្រុមហ៊ុនណាជាក់លាក់នោះទេ។ ហេតុដូច្នេះហើយទើបគេហៅថាជាអ្នកថតរូបឯកជន។ ខ្ញុំគឺជាអ្នកថតរូបដែលថា ឯករាជ្យ មិនមានអ្វីនោះឡើយ ហើយខ្ញុំមានការអប់រំខាងថតរូប ហើយខ្ញុំរៀនខ្លួនឯងផងដែរ។ គឺខ្ញុំចាប់អារម្មណ៍ជាមួយនឹងការថតរូបតាំងពីអាយុ១៣ឆ្នាំមកម្ល៉េះ។ ប៉ុន្តែនិយាយឲ្យខ្លីគឺខ្ញុំអត់មានធ្វើការឲ្យក្រុមហ៊ុន ឬក៏អង្គការណាមួយនោះឡើយ។ ខ្ញុំធ្វើការសម្រេចចិត្តស្នាក់នៅទីក្រុងភ្នំពេញក្នុង៧៥ដោយខ្លួនឯង ដោយសារតែខ្ញុំចាប់អារម្មណ៍ជាមួយនឹងការកត់ត្រាជាលក្ខណៈប្រវត្តិសាស្ត្រនានា គឺខ្ញុំសម្រេចចិត្តដោយខ្លួនឯងនៅទីក្រុងភ្នំពេញនេះ។ ខ្ញុំសង្ឃឹមថា ខ្ញុំឆ្លើយនូវសំណួរ ដែលលោកចង់សួរនោះ។

[០៩:៥៨:១៩]

**ស៖** អរគុណលោករ៉ុក្កូហ្វ។ ខ្ញុំនឹងសួរបន្តទៅទៀត សំណួរទី២ ពេលលោកបានជម្រាបតុលាការថា លោកមកភ្នំពេញលើកទី១ បាន២ខែនៅឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៣ លោកបានមកនៅភ្នំពេញហ្នឹងក្នុងរយៈ២ឆ្នាំ ដល់១៩៧៥។ ពេលហ្នឹងស្រុកខ្មែរ ប្រទេសខ្មែរហ្នឹងបានមានការវិបត្តិកាន់តែខ្លាំងឡើងៗ ហើយលោកបានធ្វើការក្នុងរយៈ២ឆ្នាំនេះបន្តទៅទៀតលោកបានចាកចេញពីភ្នំពេញ បើខ្ញុំមិនចាំ ឬក៏ខ្ញុំយល់មិនត្រូវ សូមលោកជួយកែ។ លោកចាកចេញពីភ្នំពេញនៅថ្ងៃណា ពេលណា ខែណា?

**ធ៖** ខ្ញុំជិះឡានក្បួនទី២ នៃក្បួនជនបរទេស ដែលចាកចេញពីទូតបារាំង ទៅព្រំដែនថៃ។ ខ្ញុំមិនដឹងថា ក្បួនទី១ទៅដល់ពេលណាទេ។ ប៉ុន្តែចំពោះក្បួនទី២របស់ខ្ញុំ គឺទៅដល់ថ្ងៃ០៩ ខែឧសភា។ ខ្ញុំគិតថា វាថ្ងៃ០៩ ខែឧសភា។ គឺជាក្បួនជនបរទេសចុងក្រោយគេ ដែលបានបណ្តេញចេញពីប្រទេសកម្ពុជា។ ហើយខ្ញុំចង់បញ្ជាក់ថា ២ខែក្រោយមកនោះ ខ្ញុំមិន -- ២ខែនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ៧០ហ្នឹង ខ្ញុំមិនមែនត្រឡប់មកវិញភ្លាមនោះទេ គឺខ្ញុំមកនៅឆ្នាំ៧៣ គឺបន្ទាប់ពីមានការចូលរបស់អាមេរិកមកប្រទេសកម្ពុជាមក ខ្ញុំចេញពីកម្ពុជាទៅប្រទេសវៀតណាម។ ហើយខ្ញុំត្រឡប់មកវិញ គឺខ្ញុំនៅប្រទេសកម្ពុជារយៈពេល ២ឆ្នាំក្នុងនាមជាអ្នកថតរូប គឺថាខ្ញុំជាជនស៊ីវិលទេ។ ប៉ុន្តែនៅឆ្នាំ៧០ ខ្ញុំមកហ្នឹង គឺមកជាទាហានទាហានអាមេរិក។ ដូច្នេះខុសគ្នា ឆ្នាំ៧៣ ជាជនស៊ីវិលជាអ្នកថតរូប ចំណែកឆ្នាំ៧០ជាទាហាន។

[១០:០០:៤១]

**ស៖** អរគុណ។ សំណួរចុងក្រោយរបស់ខ្ញុំ សំណួរទី៣ លោកបានជម្រាបទៅសហសេវិករបស់ខ្ញុំអំមិញថា ពេលដែលឆ្នាំ១៩៧០ នៅភ្នំពេញ លោកឃើញក្រុមទាហានខ្មែរក្រហមហ្នឹងចូលមកដល់ទីក្រុងភ្នំពេញ ពេលហ្នឹងលោកឃើញមានពីរក្រុម។ មួយក្រុម គឺខ្មែរក្រហមពិតប្រាកដ។ មួយក្រុមទៀត គឺខ្មែរក្រហមដូចជាមិនច្បាស់លាស់ ស្លៀកពាក់ស្អាតបាតអីអ៊ីចឹងទៅ។ សូមលោកធ្វើអត្ថាធិប្បាយឲ្យលម្អិតបន្ថែមបន្តិចទៀត ថាតើលក្ខណៈរបស់ដែលលោកបានសម្គាល់ហើយនោះ លក្ខណៈរបស់ទាហានខ្មែរក្រហមហ្នឹងរបៀបម៉េច ហើយនិងលក្ខណៈរបស់ខ្មែរក្រហមមិនប្រាកដហ្នឹងរបៀបម៉េច? ហើយកិច្ចការរបស់គេ ប្រតិបត្តិការនៅភ្នំពេញហ្នឹងរបៀបម៉េច? សូមអរគុណ។

**ធ៖** ដូចដែលខ្ញុំបានបញ្ជាក់រួចទៅហើយ អ្នកដែលមិនពិតហ្នឹងគឺស្លៀកពាក់ស្អាតបាតហួសហេតុ ស្បែកជើងហ្នឹងគឺឡើងរលោងចាំង គឺជាមនុស្សដែលមានលក្ខណៈមិនប្រាកដ។ ហើយមើលទៅមានលក្ខណៈថា មានម្ជុកចាំងភ្លឺផ្លេក ហើយគេបង្ហាញខ្លួននៅក្រសួងព័ត៌មាន គឺពួកនេះខុសពីក្រុមទាហានខ្មែរក្រហមដទៃទៀត គឺក្រុមដែលខ្ញុំនិយាយថាក្លែងក្លាយហ្នឹង គឺជាក្រុមដែល ស៊ីដនី សាន់ប៊ឺដ គាត់បានបង្ហាញព័ត៌មាន។ ក្រុមដែលខ្ញុំសង្កេតឃើញថាមិនពិតប្រាកដហ្នឹង គឺមិនមានវត្តមានទេនៅពេលក្រោយ។ ចំពោះទាហានពិតប្រាកដ គឺខ្ញុំឃើញខុសពីនេះ គឺមានលក្ខណៈផ្សេងពីគ្នា។ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំដឹងគឺថាមានទាហានខ្មែរក្រហមផ្សេងៗគ្នា ក្រុមផ្សេងៗគ្នា ប៉ុន្តែពួកក្រុមហ្នឹងនៅតែខ្ញុំសង្កេតឃើញថាជាក្រុមពិតប្រាកដ គឺជាទាហានខ្មែរក្រហមពិតប្រាកដ មិនមែនជាការក្លែងបន្លំនោះទេ។

[១០:០២:៥៦]

**ស៖** នៅពេលថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលហ្នឹងលោកនៅភ្នំពេញ លោកបានឃើញទាំងពីរក្រុមហ្នឹងចូលមកទាំងពីរក្រុមដំណាលគ្នា ឬក៏ក្រុមណាចូលមកមុន ក្រុមណាចូលមកក្រោយ?

**ឆ៖** ខ្មែរក្រហម គឺចូលមកភ្នំពេញរៀងរាល់ថ្ងៃ រីឯពេលងងឹតហ្នឹង គឺថាពេលដែលចូលមកទូតបារាំង ដែលខ្ញុំនិយាយពីម្សិលមិញនោះ ហើយគេមកទាំងជួរៗ គឺជាជនស៊ីវិល ហើយជាជនស៊ីវិលខាងសារព័ត៌មានបរទេស ហើយនិងកាកបាទក្រហមអន្តរជាតិ គេមកជាមួយរថយន្ត ហើយនិងមកខាងស្តាំដៃនៃផ្លូវ រីឯនៅខាងម្ខាងទៀតនៅផ្លូវមុនីវង្សនោះ គឺថាខ្មែរក្រហមទាំងជួរ គឺដើរមួយជួរ ប្រហែលជាចន្លោះពីម្នាក់ទៅម្នាក់ហ្នឹងមួយម៉ែត្រទេ។ អ៊ីចឹងគេដើរជាជួរ។ ម្តងម្កាលយើងអាចឃើញគឺថា ហើយគេមើលសម្លឹងមកយើងម្តងៗដែលនៅម្ខាងផ្លូវម្នាក់ ប៉ុន្តែជាស្ថានភាពគឺថាស្ងប់ស្ងាត់ គឺថាខ្មែរក្រហមចូលមករៀងរាល់ថ្ងៃ។ ខ្ញុំមិនអាចប្រាប់ថាប៉ុន្មានទេ ប៉ុន្តែគេមកក្នុងពេលជាមួយគ្នាផងដែរ គឺថាក្រុមទី១មកដើរហួសផុតពីទូតបារាំងនៅម៉ោងប្រាំបី។ ហើយក្រោយមក គឺថានៅវិមានឯករាជ្យនេះ គឺក្រុមខ្មែរក្រហមគឺថាមកពីខាងជើងហួសពីទូតអាមេរិកចាស់ហ្នឹងមកទីនោះ ហើយខ្ញុំមិនអាចនិយាយថា ពួកគេមកក្នុងពេលដំណាលគ្នានោះទេ ប៉ុន្តែគឺវាក្នុងលក្ខណៈបែបនោះ គឺថានៅព្រឹកនោះគឺគ្រប់ទិសដែលគេចូលមកនោះឯង។

[១០:០៥:០៤]

នៅផ្លូវជាតិលេខ៥ ខាងជើងភ្នំពេញនោះ គឺថាវាមានការប្រយុទ្ធគ្នាចុងក្រោយ មុននឹងគេចូលមកភ្នំពេញ គឺថាដេប៉ូប្រេងហ្នឹងគឺត្រូវបានគេដុត ហើយយើងមើលឃើញផ្សែងហុយទ្រលោមទៅលើ តំបន់នោះ។ អ្វីដែលខ្ញុំជម្រាបពីខាងដើមនោះ គឺថាជាទិសដៅ ជាតំបន់ដែលខ្ញុំឃើញខ្មែរក្រហមដំបូងដែលគេចូលមកនោះ។

**ស៖** អរគុណ។ ចំណុចខ្ញុំដែលចង់សួរលោក គឺត្រង់ក្រុមពួកយោធាខ្មែរក្រហម ដែលយើងហៅខ្មែរក្រហមប៉ុនមានពីរក្រុម ដូចលោកជម្រាបតុលាការអំមិញអ៊ីចឹង ចង់ដឹងបញ្ជាក់ឲ្យច្បាស់ថា ពីរក្រុមហ្នឹងលោកបានឃើញក្រុមមួយៗហ្នឹងទាហានច្រើនប្រហាក់ប្រហែលគ្នា ឬតិចឬច្រើនលើសគ្នាយ៉ាងម៉េចតាមដែលលោកឃើញ? ហើយកិច្ចប្រតិបត្តិការរបស់គេនៅក្នុងទីក្រុងភ្នំពេញនៅព្រឹកនោះ ព្រឹកដែលចូលមកថ្ងៃ១៧ មេសា ហ្នឹង តើរបៀបខុសគ្នាទេ ឬក៏មានប្រតិបត្តិការរបស់គេនៅភ្នំពេញហ្នឹងដូចគ្នា ដេញប្រជាជនចេញអ៊ីចឹងស្ទើៗ របៀបធ្វើការដូចតែគ្នា បញ្ជាតែមួយមក ឬក៏បញ្ជាខុសៗគ្នាពីលើមក បើតាមលោកបានឃើញនឹងភ្នែក?

[១០:០៦:៤៧]

**ឆ៖** នៅថ្ងៃទី១៧ មេសា ខ្ញុំមិនយល់ទេ គឺថាមិនដឹងមានច្រើនជាងមួយក្រុមទេ ប៉ុន្តែគ្រាន់តែដឹងថាមានរចនាសម្ព័ន្ធបញ្ជាខុសៗគ្នា។ ហើយខ្ញុំយល់ថាពួកគេទាំងអស់ គឺឯកភាពគ្នា។ លែកលែងតែក្រុមក្លែងក្លាយមួយទេ ដែលគេទៅប្រកាសខ្លួននៅក្រសួងព័ត៌មាន។ ហើយខ្ញុំៗមិនអាចថា មិនឃើញច្រើនទេ គឺថាក្រុមដែលក្លែងក្លាយនោះមានមួយក្រុមតូចទេ គឺស្វែងរកអ្នកសារព័ត៌មាន ជាពិសេស ស៊ីដនី សាន់ប៊ឺជ បានជាគាត់បានទៅជួប ហើយៗខ្ញុំបានដឹងភ្លាមៗថាពួកនេះមិនមែនជាខ្មែរក្រហមពិតទេ។ ប៉ុន្តែវាអាចទៅរួចដែលថាអ្វីដែលគេបានផ្សព្វផ្សាយនោះ គឺគេផ្សព្វផ្សាយឃោសនា១សប្តាហ៍មុននោះ គឺថាមានការផ្សាយតាមវិទ្យុដែលខ្ញុំបានឮ។ គេប្រាប់ខ្ញុំថា គឺខ្មែរបរទេសបានផ្តល់វិភាគទាន១លានដុល្លារ បើសិនជាអ្នកណាយកឈ្នះ ហើយនិងអាចកាន់កាប់កម្ពុជា។ ប៉ុន្តែខ្ញុំមិនដឹងថាប្រភពហ្នឹងចេញពីណាទេ។ ខ្ញុំចម្លែកដែលថាដឹងថា លន់ ណុន នៅឡើយ ដែលថានៅភ្នំពេញនៅក្រសួងសារព័ត៌មាន។ ប៉ុន្តែខ្ញុំមិនសូវច្បាស់។ ប៉ុន្តែអ្នកណាដែលផ្តល់វិភាគទាននោះ គឺខ្ញុំមិនដឹងទេ ខ្ញុំមិនដឹងថាខ្មែរក្រហមក្លែងក្លាយនេះជាពួកណាទេនៅកាលណោះ។ ប៉ុន្តែក្រោយពីហេតុការណ៍ហ្នឹងក្រោយបានខ្ញុំដឹងថាក្រុមហ្នឹងជាអ្នកណាបាទ។

[១០:០៨:២៦]

**ស៖** តើលោក រ៉ុក្ហូ បានព័ត៌មានពីណាមកថា ពួកទៅក្រសួងឃោនាការដើម្បីផ្សាយព័ត៌មានអីទាំងអស់ហ្នឹង ជាពួកក្លែងក្លាយ? ព័ត៌មានហ្នឹងលោកបានពីណា ច្បាស់លាស់ទេ?

**ឆ៖** មិនមែនពេលដែលខ្ញុំនៅទីនោះទេ គឺថាយូរហើយដែល -- យូរពីហ្នឹងមកដែលខ្ញុំអានសារព័ត៌មានញូវយ៉កថែមស៍ ពេលនោះគឺថា ស៊ីដនី សាន់ប៊ឺជ ជាអ្នកពន្យល់ថា នេះគេមិនមែនខ្មែរក្រហមពិតប្រាកដទេ ប៉ុន្តែពួកគេមិនមែនជាអ្នកទទួលខុសត្រូវក្នុងការជ័យជម្នះក្នុងការអ្វីៗផ្សេងៗទេ។ ហើយគាត់មានឱកាសជួបជាមួយក្រុមនោះ សាន់ប៊ឺជ ហ្នឹងគឺថា ហើយគាត់បានដឹងថា ដឹងហើយ ឌិត ប្រាន (Dith Pran) ដែលបានជួយ សាន់ប៊ឺជ ដែរគាត់ ឌិត ប្រាន ហ្នឹងបញ្ជាក់ថា គាត់សង្ស័យថាពួកនេះមិនមែនខ្មែរក្រហមពិតទេ។ ហើយខ្ញុំមិនបានដឹងទេសម័យពេលនោះ ប៉ុន្តែក្រោយមកយូរ ទើបបានខ្ញុំដឹង។ ពិភពខាងក្រៅដែលដឹងថាពីអ្វីកើតឡើងនៅទីនេះ ក្រុមណាៗហ្នឹង។

និយាយពីខ្លឹមសារនៃរចនាសម្ព័ន្ធភាគីនយោបាយជាដើមហ្នឹង គឺថាយើងមិនសូវបានដឹងទេ ប៉ុន្តែយើងតែងតែឮរឿងរ៉ាវមួយចំនួនដូចដែលខ្ញុំនិយាយពីខាងដើម គឺថាដែលថាខ្មែររំដោះមានគ្នា៦០០នាក់

ដែលចុះចូល លន់ នល់ នោះ ខ្ញុំបានដឹងក្រោយមុនហេតុការណ៍ដោយសារតែការទំនាក់ទំនងជាច្រើន ដែលខ្ញុំត្រូវសរសេរជាមួយអ្នកសារព័ត៌មានអូស្ត្រាលី ហើយអ្នកថតរូប ដេវីស (Neil Davis) ហើយ និងអ្នកបើកបររបស់គាត់ផងដែរ បានដឹងអំពីក្រុមទាំងអស់នេះ គេចុះចូលមករដ្ឋាភិបាលលន់ នល់។ ហើយគេបាននៅទីនោះ -- ហើយគេពួកអ្នកហ្នឹងគឺបានពួកហ្នឹងឃុំខ្លួនប៉ុន្មានម៉ោង ប៉ុន្តែក្រោយមកគេ សម្រេចចិត្ត ហើយកម្មាភិបាលពួកនោះ ដែលទទួលបន្ទុកនោះ បានជជែកជាមួយពួកយើង ហើយពួក គេនិយាយភាសាបារាំង ដែលខ្ញុំស្តាប់បារាំងមិនបានទេ ប៉ុន្តែខ្ញុំបានដឹងតាមរយៈក្រុមការងារជាមួយ នោះ។ ការៗប្រគល់អាវុធទៅឱ្យរដ្ឋាភិបាលគឺ ២-៣ថ្ងៃក្រោយមកហ្នឹង នៅពេលដែល -- ខ្ញុំជិតភ្លេច ចំណុចមួយគឺសូមជម្រាប ហើយគេសួរខ្ញុំថា តើខ្ញុំជាអ្នកណា? មកពីណា? គេសួរខ្ញុំអ៊ីចឹង។ ហើយគេ សួរថាអ្នកឯងរស់នៅទីណា? ហើយ ខ្ញុំឆ្លើយថា នៅអូតែលមួយនៅភ្នំពេញ។ ហើយគេប្រាប់ឈ្មោះ អូតែលខ្ញុំ ថាតើអូតែលអី? ឥឡូវនេះគេហៅថាអូតែលអាស៊ី។ ហើយគាត់ក៏ដឹងដែរ។ ហើយគេស្គាល់ ដេវីស ពេលដែល ដេវីស គាត់បានទៅទីនោះ។ ហើយខ្ញុំបានទៅជាមួយគាត់ដើម្បីរាយការណ៍ទាក់ទង នឹងហេតុការណ៍នៅថ្ងៃនោះ។ គឺគាត់ -- ខ្ញុំយល់ថានេះជាបទពិសោធន៍គួរឱ្យចាប់អារម្មណ៍មួយ។

ភាគីនៃក្រុម ៦០០នាក់នេះ ដែលគេចុះចូលរដ្ឋាភិបាល លន់ នល់ មិនដែលបង្កើតជាការចុះចូលធំ បែបនេះទេពីមុនមកនោះ។ ហើយខ្ញុំយល់ថា ក្រុមនេះដូចខ្មែរក្រហមផ្សេងទៀត គេហៅថាគេ "ខ្មែរ រំដោះ" កាលពីដើមពួកគេ គាំទ្រសម្តេចសីហនុ។

**ស៖** អរគុណ។ បើអ៊ីចឹងលោកមានប្រសាសន៍ទាំងអស់នេះមានន័យថាលោកអត់បានឮផ្ទាល់ ថាពួកក្រុមខ្មែរក្រហមក្លែងក្លាយហ្នឹងទៅក្រសួងឃោសនាការពេលនោះទេ គឺលោកបានព័ត៌មានក្រោយ មក ទេ អឺ! ខ្ញុំខុសឬត្រូវ?

**ឆ៖** អ្វីដែល ស៊ីដនី សាន់ប៊ឺជ បានសរសេរនោះទាក់ទងអំពីធម្មនុរូបនៃក្រុមនេះ ភាពពិត ប្រាកដនោះគឺថា ២-៣សប្តាហ៍ក្រោយពីហ្នឹង ក្រោយពីគាត់បានបញ្ជូនព័ត៌មានទៅសហរដ្ឋអាមេរិក។ ក្រោយមកខ្ញុំមិនបានពិភាក្សាអំពីព័ត៌មានដែលខ្ញុំទទួលបាន មិនធ្វើការឱ្យក្រុមហ៊ុនមួយដែលមានអ្នកបើក បរ អ្នកបកប្រែ ខ្ញុំឃើញថាម្នាក់ៗតែងតែមានអ្នកបកប្រែ មាន ឌិត ប្រាន ក៏បានពន្យល់ទៅ ស៊ីដនី សាន់ប៊ឺជ។ គាត់ក៏បានពន្យល់មកខ្ញុំដែរអំពីហេតុការណ៍នោះ។ នេះហើយជារបៀបដែលខ្ញុំបានព័ត៌មាន ទិន្នន័យជម្រាបនោះ។ វាមានសារៈសំខាន់ណាស់ដែលខ្ញុំដឹងព័ត៌មានទាំងអស់នេះ ជាពិសេសអំពី អ្វីដែល គេសួរខ្ញុំថា ខ្ញុំសង្កេតឃើញអ្វីខ្លះទាក់ទងទៅនឹងការផ្តោះប្តូរព័ត៌មាននោះ។ ដោយថាខ្ញុំមិននិយាយ មិន

ចេះនិយាយភាសាខ្មែរទេ ប៉ុន្តែខ្ញុំឆ្ងល់ហើយសួរគេ ហើយនៅពេលដែលយើងមានជំនួយការគួរឲ្យទុកចិត្តដូចជា ឌិត ប្រាន ហើយនិងអ្នកបើកបររបស់ ដេវីស ដែលចេះភាសាអង់គ្លេសដែរនោះ គឺថាយើងអាចធ្វើការបាន យើងអាចសួរហើយដឹងព័ត៌មានបាន។

**ស៖** អរគុណ។ លោកបានឃើញក្រុមខ្មែរក្រហមពីរក្រុមខុសគ្នា ហើយកិច្ចប្រតិបត្តិការនៅភ្នំពេញចូលមកថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥នុ៎ង ការងារដែលធ្វើហ្នឹងបែបវាខុសគ្នា បើតាមលោកមានប្រសាសន៍រួចមកហើយ។ លោកពេលថ្ងៃ១៧ មេសា ហ្នឹងលោកនៅភ្នំពេញដែរ? អំមិញនេះលោកបានជម្រាបអង្គសវនាការថា សុទ្ធតែមានអ្នកបកប្រែដូចជនបរទេស ដូចជាអ្នកកាសែតក្ដី។ ប៉ុន្តែពេលនុ៎ងលោកបានឮវ៉ាដ្យូផ្សាយ ហើយមានឮបកប្រែថាអ្នកឡើងទៅហ្នឹងជាជន ជាក្រុមខ្មែរក្រហមមួយណាទេ លោកមានច្បាស់លាស់ត្រង់ហ្នឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១០:១៥:១៨]

**លោក ខេល លីសាក់៖**

ខ្ញុំសូមជំទាស់នឹងសំណួរនេះ លោកប្រធាន។ គឺមេធាវី ហើយលើកឡើងពីបញ្ហាច្រំដែលទាក់ទងទៅនឹងបញ្ហានេះពីរបីដង ប្រហែលជាគាត់មិនពេញចិត្តនឹងចម្លើយរបស់សាក្សី គាត់អាចនឹងគឺថាគាត់មិនមែនថាឃើញក្រុមខ្មែរក្រហមពីរទេ គាត់ថាឃើញក្រុមមួយក្រុមដែលតាំងខ្លួនធ្វើជាខ្មែរក្រហម។ រីឯមេធាវីគាត់បន្តនិយាយធ្វើឲ្យសាក្សីភ័ន្តច្រឡំ ហើយរហូតទៅដល់និយាយថា មានការផ្សព្វផ្សាយតាមវិទ្យុតើលោកឮបានដូចម្ដេច។ ដូច្នេះហើយគឺថា សាក្សីបានបញ្ជាក់ហើយថា ក្រុមមួយនោះគឺជាក្រុមនៅក្រសួងព័ត៌មាន រីឯក្រុមខ្មែរក្រហមផ្សេងទៀត គឺមានច្រើនក្រុម នៅកន្លែងផ្សេង។ ដូច្នេះសូមសហព្រះរាជអាជ្ញាសូមជំទាស់នឹងសំណួរនេះបាទ។

**លោក សុន អរុណ៖**

ខ្ញុំសូម -- លោកប្រធានអនុញ្ញាតឆ្លើយទៅនឹងព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាខ្លួនឯងក៏បាននិយាយដែរ ក្រុមមិនមែនខ្មែរក្រហមពិតហ្នឹង ដែលស្លៀកពាក់ត្រឹមត្រូវ មានន័យថាពីរក្រុមរួចទៅហើយ។ មានន័យថាពីរក្រុមរួចទៅហើយ មួយក្រុមខ្មែរក្រហមពិតប្រាកដ មួយមិនខ្មែរក្រហមពិតប្រាកដ។ ត្រង់ហ្នឹងខ្ញុំចង់បានត្រង់ហ្នឹង តើសាក្សីបានឃើញហ្នឹង ពេលហ្នឹងគឺខ្មែរក្រហមពិតប្រាកដប្រតិបត្តិការយ៉ាង

ម៉េច? ក្រុមគេយ៉ាងម៉េច ហើយមិនខ្មែរក្រហមពិតប្រាកដយ៉ាងម៉េច។ អានេះជាប្រវត្តិសាស្ត្រ។ ហើយនៅក្នុងអង្គសេចក្ដីដែលក្នុង ០០២ ឬក្នុង ១៩៧០ ដើម ១៩៧០។

[១០:១៦:៥៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១៧:២០]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាមានមូលដ្ឋានត្រឹមត្រូវ។ សំណួរនេះពិតជាច្រំដែរ ហើយសួរសាចុះសាឡើង ធ្វើឲ្យសាក្សីមានការភ័ន្តច្រឡំ។ ដូច្នេះ សាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយ ដោយមេធាវីការពារក្ដីលោក នួន ជា ទេ។

**លោក សុន អរុណ៖**

ខ្ញុំអស់សំណួរ។ សូមអរគុណលោកប្រធាន។ សូមអរគុណ រ៉ុក្ហូ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនក្រុមមេធាវីការពារក្ដីលោក អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

[១០:១៨:០៩]

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់ ទាំងក្នុងក្រៅសាលសវនាការ ហើយសូមជម្រាបសួរលោក អាល់ រ៉ុក្ហូ។ យើងខ្ញុំអរគុណដែលលោកបានអញ្ជើញមកផ្ដល់ភស្តុតាងដល់តុលាការនេះ ហើយខ្ញុំសរសើរចំពោះចម្លើយដ៏ស្មោះត្រង់ ហើយសូមជូនពរឲ្យលោកមានសំណាងបំផុត ហើយឲ្យមានសុវត្ថិភាពក្នុងការធ្វើដំណើរ។ សូមអរគុណលោក លោកស្រីចៅក្រម។ ខ្ញុំអត់មានសំណួរអ្វីទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។

[១០:១៩:០០]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក រ៉ូកូហ្វ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីការពារក្តីលោក ខៀវ សំផន។ ខ្ញុំសួរសំណួរលោកមួយចំនួនយោងទៅតាមអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញ ហើយនិងព្រឹកនេះ។ វាគ្រាន់តែជាសំណួរបញ្ជាក់បន្ថែម ហើយសំណួរខ្ញុំខ្លីទេ។ ចំណុចដំបូងនោះខ្ញុំចង់ត្រឡប់ក្រោយបន្តិច ពាក់ព័ន្ធទៅនឹងខ្សែជីវិតលោកជាយោធានៅមុនឆ្នាំ៧៣។ លោកបានបញ្ជាក់ថាជាធ្វើជាយោធានៅក្នុងកងទ័ពអាមេរិក។ តើលោកអាចបញ្ជាក់បានទេ ថាលោកចូលធ្វើទាហានហ្នឹងនៅឆ្នាំដែរ? ហើយចូលនៅក្នុងកងទ័ពផ្នែកអ្វីដែរ?

**លោក អាល់ រ៉ូកូហ្វ៖**

**ឆ៖** ជារឿងរ៉ាវវែងណាស់ ដូចដែលខ្ញុំលើកឡើងនៅក្នុងវិតីភីឌា ខ្ញុំនៅសហរដ្ឋអាមេរិក១ឆ្នាំមុនដែលគេបញ្ជូនមកធ្វើការ។ ក្រោយមកខ្ញុំចុះឈ្មោះធ្វើជាទាហាន ហើយធ្វើភារកិច្ចគឺថា មានការងារមួយចំនួននៅយោធា។ ខ្ញុំគេបញ្ជូនមកវៀតណាម ហើយខ្ញុំក៏បានធ្វើការជាអ្នកថតរូបខ្លះដែរ។ ហើយខ្ញុំនៅកាលនោះបទពិសោធន៍ទី១ ជាមួយការថតរូបនេះ គឺនៅពេលដែលខ្ញុំនៅប្រទេសអាល្លឺម៉ង់។ ខ្ញុំបានរៀនសូត្រជាច្រើនស្ថិតនៅប្រទេសអាល្លឺម៉ង់ ទាក់ទងទៅនឹងជំនាញខាងថតរូបនេះ។ ហើយខ្ញុំមកវៀត-ណាមក្នុងកងទ័ព ហើយខ្ញុំពិនិត្យឃើញថា ខ្ញុំ -- គេបញ្ជូនខ្ញុំមក២ខែ នៅក្នុងឆ្នាំ១៩៧០ ពីចំពោះ ២ខែ ហើយខ្ញុំក៏បានធ្វើការថតរូបដែរអង្កាល់ណោះ។ ខ្ញុំជាយោធាទទួលបន្ទុកខាងថតរូបបាទ។

**ស៖** សូមអរគុណ។ លោកដូចជាឆ្លើយទៅនឹងសំណួរទី២របស់ខ្ញុំរួចទៅហើយ ដែលខ្ញុំចង់ដឹងថា តើលោកមកក្នុងឆ្នាំ៧០ នុ៎ងក្នុងក្របខ័ណ្ឌអ្វីជា គឺថាជាអ្នកថតរូបឲ្យយោធាក្នុងរយៈពេល ២ខែ។ ខ្ញុំមាន ខ្ញុំចង់បានការបញ្ជាក់ឲ្យបានច្បាស់ព្រោះថា អម្បាញ់មិញនេះ ខ្ញុំមិនបានឮលោកនិយាយសោះថា តើលោកអាយុប៉ុន្មានដែរនៅពេលដែលលោកចូលធ្វើជាយោធានេះ?

[១០:២១:៣៣]

**ឆ៖** គឺខ្ញុំអាយុ១៧ -- ខ្ញុំអាយុ១៦ នៅពេលដែលខ្ញុំ -- គេចុះឈ្មោះជាកងយោធា អាយុ១៦ គេបដិសេធ ប៉ុន្តែខ្ញុំមកដល់វៀតណាមខ្ញុំអាយុ១៨ ឆ្នាំជាយោធានោះ។

**ស៖** សូមអរគុណលោកចំពោះការឆ្លើយបំភ្លឺនេះ។ ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកនិយាយអំពីរយៈពេលមួយដែលលោកបានតាមទាហាន លន់ នល់ នៅឆ្នាំ៧៣ ដល់ឆ្នាំ៧៥ លោកបានឆ្លើយជូនសហព្រះរាជអាជ្ញា ក៏ដូចជាខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីអំពីការធ្វើដំណើរយ៉ាងលំបាកនៅសម័យនោះ។ ហើយលោកពន្យល់ថា មូលហេតុដែលមានការលំបាកក្នុងការធ្វើដំណើរ ហើយបើលោកអាចធ្វើដំណើរបាននោះ គឺដោយសារតែលោកបានទៅតាមទាហានរបស់ លន់ នល់ ទេ ទើបលោកអាចធ្វើដំណើរបាននោះ។ ដូច្នេះសំណួរដំបូងរបស់ខ្ញុំពាក់ព័ន្ធទៅនឹងចំណុចនេះ ខ្ញុំចង់ដឹងថា តើលោកតែងតែទៅតាមទាហាន លន់ នល់ នេះ ឬក៏យ៉ាងម៉េច? ឬក៏ការងារលោកគឺត្រូវតែទៅតាមពួកទាហានទាំងអស់នុ៎ង តើលោកទៅតាមហ្នឹងយ៉ាងម៉េចដែរកម្រិតញឹកញាប់យ៉ាងណាដែរ?

[១០:២២:៥៥]

**ឆ៖** បាទ ទៅជាមួយទាហាន លន់ នល់ នុ៎ងគឺមិនពិបាកទេ។ ការពិបាក គឺចូលទៅដល់កន្លែងមួយមូលដ្ឋានដែលគេឈរជើងនុ៎ង គឺថាគឺពេលខ្លះ គឺថាយើងទៅតាមមន្ទីរពេទ្យ ប៉ុន្តែយើងទៅកន្លែងដែលប្រយុទ្ធដែរ។ ប៉ុន្តែបើយើងត្រូវទៅខ្សែត្រៀមនោះ យើងត្រូវទៅជាមួយឡានអំប៊ូឡង់ បាទ។ អ៊ីចឹងហើយគឺថា នៅអូតែលអាស៊ីនោះ គឺថាមានអូតែលមួយនៅក្បែរហ្នឹងដែរ អូតែលសន្តិភាព។ អ៊ីចឹងគឺថាមនុស្សដែលជាម្ចាស់អូតែលនោះ គឺគេអនុញ្ញាតឲ្យយើងនៅថ្នាក់លើបំផុត គឺថាគេប្រមូលសិស្សយោធាអ៎! សិស្សខាងពេទ្យ ដើម្បីឲ្យទៅធ្វើពេទ្យទាហាន។ ហើយខ្ញុំអាចក្រោកពីម៉ោងបួនព្រឹក បាទ ឬក៏បួនសាបសិបនាទី ហើយអំប៊ូឡង់ក៏បានមកយកយើង ហើយយើងក៏ទៅជាមួយពេទ្យហ្នឹង ហើយទៅសមរភូមិ ទៅផ្លូវជាតិលេខ៤ ជួនកាល ៗផ្លូវជាតិលេខ៥ តាមបណ្ដោយទន្លេសាប។

[១០:២៤:១២]

ហើយនៅពេលដែលយើងតាមឡានអំប៊ូឡង់នោះ គឺថាយើងធ្វើម៉េចចេញពីព្រលឹមមុនថ្ងៃរះ។ ជាពិសេសកងទាហាន ជាមួយនិងពេទ្យហ្នឹង គឺថាត្រូវប្រយុទ្ធនៅខ្សែត្រៀមខាងមុខ ហើយនិងខ្សែត្រៀមខាងក្រោយនោះផងដែរ។ ការដែលយើងទៅខ្សែត្រៀមសមរភូមិនោះ មិនពិបាកទេ ហើយខ្ញុំមិននៅខាងក្រៅរហូតដល់ម៉ោងប្រាំបី ម៉ោងប្រាំពីរទៅម៉ោង -- ក្រសួងព័ត៌មានដូចអ្នកផ្សេងទេ។ ម្ដងម្កាលទេ ខ្ញុំធ្វើបែបនោះ ប៉ុន្តែភាគច្រើនខ្ញុំទៅតាមពួកពេទ្យ គឺថាចាប់ផ្ដើមពីព្រឹកដើម្បីកំណត់ថាពេលណាយើងចង់ទៅ គឺថាយើងត្រូវត្រៀមរៀបខ្លួនដើម្បីទៅទីនោះ។ ហើយបើយើងធ្វើការថតសម្រាប់ទូរទស្សន៍យើងត្រូវតែរៀបចំខ្លួននៅកន្លែងណាដែលយើងបានរូបល្អ។ ដូច្នេះហើយយើងត្រូវក្រោកពីព្រលឹម ហើយ

សិស្សពេទ្យទាហានហ្នឹង គឺថាពួកមេឌិកហ្នឹង គឺថាយើងក្រោកជាមួយដំណាលពួកគេ ហើយយើងងាយស្រួលទៅជាមួយគាត់។ ហើយយើងទៅថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៧៣ ហ្នឹង គឺថាខ្ញុំទៅកំពង់ឆ្នាំង គឺនៅពេលនោះហើយដែលខ្ញុំត្រូវអំបែងគ្រាប់ចំដៃខ្ញុំនោះ។ ហើយមុនពេលដែលរបួសនោះខ្ញុំនៅមន្ទីរពេទ្យមួយនៅកំពង់ឆ្នាំង។ ខ្ញុំចង់រកឃើញថា តើវាមានអ្វីកើតឡើងនៅទីនោះ ហើយខ្ញុំទៅនេះដើម្បីប្រមូលទៅរកសាកសពរបស់ លឹម សុវ៉ាត ជាអ្នកថតរូបខ្មែរ ដែលស្លាប់ពីមួយថ្ងៃមុន ហើយខ្ញុំទៅជួបវេជ្ជបណ្ឌិត ហើយគាត់នោះដេញខ្ញុំចេញ។ គេសួរថា អ្នកឯងមកធ្វើអី មកធ្វើអី? ទៅចេញពីមន្ទីរពេទ្យជាប្រញាប់! គេប្រាប់អ៊ីចឹង។ ហើយខ្ញុំជាអ្នកថតរូប គឺខ្ញុំចង់ថតរូប។ ខ្ញុំដឹង យើងបានរកឃើញសាកសពរបស់ លឹម សុវ៉ាត បន្ទាប់មកខ្ញុំរងរបួស ហើយគេបញ្ជូនទៅមន្ទីរពេទ្យអំមិញដែលគេដេញខ្ញុំនោះឯង។ ហើយក៏គេបានព្យាបាលខ្ញុំពីរបួសនោះ។

[១០:២៦:២០]

**ស៖** តាមការឆ្លើយដ៏លម្អិតរបស់លោកនោះ គឺថា ខ្ញុំអាចយល់បានថា នៅចន្លោះឆ្នាំ៧៣ ឆ្នាំ៧៥ នោះ ការងាររបស់លោកនោះគឺថា តាមដានព័ត៌មានអំពីការប្រយុទ្ធគ្នានៅសមរភូមិ តើនេះគឺជាអ្វីដែលលោកចង់ឆ្លើយជូនខ្ញុំមែនទេ?

**ឆ៖** ខ្ញុំអាចឆ្លើយបំភ្លឺបាន នេះជាព័ត៌មានត្រឹមត្រូវ ការបកស្រាយរបស់លោកស្រីនោះ។ ខ្ញុំបានថតរូបច្រើនណាស់នៅទីកន្លែងជនភៀសខ្លួន ហើយការងាររបស់ខ្ញុំដោយស្ម័គ្រចិត្តទេ អត់មានគិតថ្លៃទេ។ ហើយខ្ញុំធ្វើការមួយចំនួនថតរូបឱ្យកាកបាទក្រហមអន្តរជាតិ ហើយខ្ញុំពេញចិត្តនឹងធ្វើអាហ្នឹង ហើយគេផ្តល់លទ្ធភាពឱ្យខ្ញុំចូលទៅកន្លែងមួយចំនួន។ ហើយខ្ញុំធ្វើឱ្យ កាតូលិករីលីស សឺវីស ផងដែរ ជាអង្គការមួយ ស៊ី.អ័រ.អេស ហើយមានការសំខាន់ណាស់ គឺថាមានមនុស្សជនភៀសខ្លួនច្រើនជាង ៤០០.០០០នាក់ឯណោះ គឺថាយើង -- ហើយយើងត្រូវតែធ្វើដំណើរទៅកន្លែងណាឱ្យផុតពីកន្លែងធ្លាក់គ្រាប់ផ្លោង រ៉ុក្កែតនុ៎ង គឺថា ធ្វើម៉េចពេលខ្លះឱ្យជៀសផុតពី១០៧ មីលីម៉ែត្រជាដើមហ្នឹង ជាទំហំគ្រាប់បែក។ អ៊ីចឹងហើយគឺ បើយើងត្រូវនៅឱ្យឆ្ងាយពីមណ្ឌលយោធា។ ជួនកាលខ្មែរក្រហមអាចផ្លោងដាក់ ហើយយើងត្រូវតែចេញពីកន្លែងនេះ។ ជួនកាលគឺមួយម៉ោង ពីរម៉ោង យើងត្រូវពីកន្លែងហ្នឹង។ អ៊ីចឹងគឺថា យើងត្រូវធ្វើការងារប្រញាប់។ មានការត្រូវការជាចាំបាច់នូវព័ត៌មានថាតើសមរភូមិមុខនៅចម្ងាយប៉ុន្មាន។ តើទីក្រុង ទីប្រជុំជនណា ដូចកំពង់ស្ពឺ ដែលជិតនឹងត្រូវដួលរលំជាដើមហ្នឹង គឺយើង -- នេះជាបញ្ហាពាក់ព័ន្ធដែលយើងត្រូវរាយការណ៍ យើងត្រូវថតឱ្យបាន។ ហើយនិងការភៀសខ្លួនរបស់ជន

ភៀសខ្លួននៅតំបន់នោះ ហើយយើងត្រូវតែផ្សាយ យើងត្រូវតែថតរូបឲ្យបានជាដើម។ ហើយយើងថត មិនត្រឹមតែសង្គ្រាមតែប៉ុណ្ណោះ ហើយយើងត្រូវថតអ្វីៗជុំវិញហ្នឹងទាំងអស់។

[១០:២៨:៣៣]

**ស៖** ខ្ញុំសូមត្រឡប់មកនិយាយលម្អិតអំពីជនភៀសខ្លួននៅពេលក្រោយ។ ក៏ប៉ុន្តែជាដំបូងនោះខ្ញុំចង់និយាយអំពីបេសកកម្មរបស់លោកជាអ្នកថតរូបនៅជាមួយទាហាន លន់ នល់។ ឥឡូវនេះ ខ្ញុំសូមត្រឡប់មកបង្ហាញរូបថត ដែលបង្ហាញដោយចៅក្រម ឡាវែន៍ កាលពីម្សិលមិញ។

ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញរូបថតដែលលោកចៅក្រម ឡាវែន៍ បានដកចេញមកពីអ៊ីនធឺណេត គឺរូបថតដែលក្នុងនោះមានទាហានខ្មែរក្រហមក្មេងដែលមានកាន់កាំភ្លើង ហើយមានដាក់ផ្កានៅលើមួក។ ខ្ញុំគិតថា លោកប្រធានពិតជាយល់អំពីរូបភាពដែលខ្ញុំចង់បង្ហាញនេះហើយ។ ដូច្នេះ សូមការអនុញ្ញាត ដើម្បីបញ្ចាំងរូបភាពនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយកញ្ញា អង់តា ហ្គីសេ៖**

**ស៖** នៅលើរូបថតនេះ ខ្ញុំមានសំណួរតែមួយទេ ព្រោះថាម្សិលមិញនោះគឺថាដូចជាមិនសូវច្បាស់។ យើងយល់បានថា រូបថតនេះគឺជាទាហាន លន់ នល់ ដែលលោកបានថតក្នុងក្របខ័ណ្ឌនៃការយកការណ៍របស់លោកជាមួយនឹងកងទ័ព លន់ នល់ តើអ៊ីចឹងមែនទេ?

**លោក អាល់ រ៉ុក្កូហ្វ៖**

**ឆ៖** បាទ ពិតហើយជាទាហានរបស់រដ្ឋាភិបាល លន់ នល់។

*(សម្រាករយៈពេលខ្លី)*

**ប្រធានអង្គជំនុំ៖**

មិនទាន់ឃើញមានរូបភាពទេ។

[១០:៣០:៤៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសាក្សីឆ្លើយតបនឹងសំណួរ!

**លោក អាល់ រ៉ុក្ហូហ្វ៖**

**ឆ៖** បាទ នេះជាទាហានរបស់លន់ នល់។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ឥឡូវនេះខ្ញុំចូលទៅប្រធានបទផ្សេងទៀត លោកបានឆ្លើយជូនសហព្រះរាជអាជ្ញា--

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។ ឥឡូវនេះដោយសារត្រូវឆ្លងទៅប្រធានបទផ្សេងផង ហើយដល់ពេលសមល្មមសម្រាកហើយ។ ឥឡូវអង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកដល់សាក្សីរូបនេះនៅក្នុងពេលអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោង--

*(សម្រាករយៈពេលខ្លី)*

លោកស្រីមេធាវី តើទំនងលោកស្រីប្រើប្រាស់ពេលវេលាប្រហែលជាប៉ុន្មានទៀត?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំបញ្ជាក់ជូនម្សិលមិញហើយ ថាខ្ញុំត្រូវការប្រហែលជា២០ ឬក៏៣០នាទី។ ដូច្នេះខ្ញុំបញ្ជាក់ថា ខ្ញុំត្រូវការប្រហែលជា២៥នាទីទៀតបន្ទាប់ពីការសម្រាកហើយ។ លើកលែងតែខ្ញុំអាចទៅលឿនជាងនេះ។ ដូច្នេះដើម្បីកុំឲ្យជាន់កែងខ្លួនឯង គឺខ្ញុំត្រូវការ២៥នាទីយ៉ាងហោចណាស់។

**ប្រធានអង្គជំនុំ៖**

បាទ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង ១០:៥៧ នាទី)*

[១០:៥៧:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណ លោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក រ៉ុកូហ្វ ខ្ញុំត្រឡប់មកនិយាយអំពីអ្វីដែលខ្ញុំបានឈប់មុនពេលសម្រាកវិញ។ លោកបានបញ្ជាក់ថាលោកបានចាំច្បាស់អំពីការទម្លាក់គ្រាប់បែក បេ-៥២ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ៧៣។ សំណួររបស់ខ្ញុំ ខ្ញុំចង់ដឹងថាបើតាមលោកដឹងតើទាហាន លន់ នល់ នោះមានមូលដ្ឋានទ័ពអាកាសដែរឬទេ?

**លោក អាល់ រ៉ុកូហ្វ៖**

**ឆ៖** ខ្ញុំមិនចាត់ទុកថាវាជាកងអាកាស ឬក៏ជាបណ្តុំយន្តហោះនោះទេ។ ព្រោះថានៅថ្ងៃ១៥ ខែ៨ គឺថានៅពេលនោះគឺទាហានអាកាសខ្មែរមានតិចតួចទេ មានឧទ្ធម្ភាគចក្រដើម្បី នៅពេលនោះគឺមានការទម្លាក់គ្រាប់បែកពីយន្តហោះ គឺទម្លាក់គ្រាប់បែកបេ-៥២ ហើយកងទ័ពអាកាសខ្មែរដូចជាមិនមានសមត្ថភាពនោះទេ។ ខ្ញុំមិនអាចកំណត់បញ្ជាបានថាតើមានចំនួនប៉ុន្មាននោះទេ នៅពេលនោះ។

[១០:៥៩:១៨]

ហើយនៅពេលនោះគឺមានយន្តហោះ សេ-៤៧ ជាដើម សេ-១២៣ ក៏ជាកម្លាំងទ័ពអាកាសរបស់អាមេរិកផងដែរ ប៉ុន្តែនៅពេលនោះគឺមានចំនួនតិចតួចទេ ប្រសិនបើធៀបជាមួយនឹងចំនួនអាមេរិកគឺកម្ពុជាមានចំនួនតិចតួចបំផុត។ គឺថានៅត្រឹមថ្ងៃ០៥ ខែ៨ នោះគឺថាទាហានខ្មែរមានកម្លាំងទ័ពអាកាសតិចតួចបំផុត។

**ស៖** នេះជាការសន្និដ្ឋានសមហេតុផលចំពោះខ្ញុំ។ ប្រសិនបើកាត់បន្ថយ៨៥ភាគរយនោះគឺថា ៥ភាគរយនៃការទម្លាក់គ្រាប់បែកដូចអ្វីដែលលោកបានរៀបរាប់អម្បាញ់មិញនេះ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ គឺថាអាវុធគ្រាប់រំសេវត្រូវបានគេនាំយកចូលមកប្រទេសខ្មែរ ហើយការទម្លាក់គ្រាប់

បែកគឺមិនមែនមានប្រភពចេញមកពីខ្មែរនោះទេ គឺជាការទម្លាក់របស់អាមេរិក។ មូលដ្ឋានទ័ពអាកាសខ្មែរនៅពោធិ៍ចិនតុងហ្នឹងគឺថាមានលក្ខណៈទន់ខ្សោយតិចតួចបំផុត គឺមិនអាចនិយាយថាជាការទម្លាក់របស់ខាងកម្ពុជានោះទេ វាគ្រាន់តែជាយុទ្ធសាស្ត្រ ឬក៏គាត់ទិកទាហាន លន់ នល់ ប្រើប្រាស់ប៉ុណ្ណោះ តែមិនអាចទម្លាក់គ្រាប់បែកបានទេ។

[១១:០១:០៣]

**ស៖** នៅពេលដែលលោកនិយាយថា មានបញ្ហាខាងផ្នែកមធ្យោបាយប្រើប្រាស់នោះ តើចង់មានន័យថាម៉េចដែរ? ថាអំពីថាយុទ្ធសាស្ត្រ ឬគាត់ទិកដែលប្រើប្រាស់នោះ តើលោកចង់មានន័យថាយ៉ាងម៉េច?

**ឆ៖** នៅពេលដែលអាមេរិកគាំទ្រ កម្ពុជាគឺការទម្លាក់គ្រាប់បែកអាមេរិកហ្នឹងគឺជាការជួយដល់ខាងរដ្ឋាភិបាលកម្ពុជា។ គឺថាកម្ពុជាពឹងផ្អែកទៅលើអាមេរិកនៅពេលនោះ។ ទ័ពអាកាសខ្មែរនៅពេលនោះគឺមានលក្ខណៈទន់ខ្សោយ តិចតួចបំផុត។ ដូច្នេះគឺមិនអាចពឹងផ្អែកទៅលើទ័ពអាកាសខ្មែរបានទេ។ កងទ័ពជើងគោកគឺមានការប្រុងប្រយ័ត្នមែនទែន នៅពេលដែលត្រូវរៀបចំទ័ព នៅពេលដែលមានការទម្លាក់ផង នៅពេលដែលរៀបចំទ័ពជើងគោកផង។ ដូច្នេះកងទ័ពជើងគោក គឺព្យាយាមរៀបយ៉ាងម៉េចកុំឲ្យមានការទម្លាក់គ្រាប់បែកចំ នេះគឺកាត់ផ្តាច់ ឧទាហរណ៍ដូចជាវត្តគឺទាហាន លន់ នល់ បោះទីតាំងនៅទីនោះ ហើយទាហានខ្មែរក្រហមនៅព័ទ្ធជុំវិញវត្តនោះជាដើម។ ហើយទាហានអាមេរិកគឺទម្លាក់គ្រាប់បែកតែជុំវិញវត្តទេ មិនទម្លាក់មកលើវត្តដែលជាមូលដ្ឋានរបស់ទាហាន លន់ នល់ នោះឡើយ។ នេះគឺជាវិធីសាស្ត្រមួយដែលកើតឡើងនៅពេលនោះ។

[១១:០៣:៣២]

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់។ ឥឡូវនោះខ្ញុំចូលទៅប្រធានបទផ្សេងទៀត។ ខ្ញុំចង់បានការបំភ្លឺពាក់ព័ន្ធទៅនឹងរូបថតដែលបានបង្ហាញជូនលោកកាលពីម្សិលមិញ ដោយលោកចៅក្រមឡាវ៉ែន៍ ហើយដែលជាឯកសារដែលផ្ញើតាមម៉ែលដោយ ឌី.ស៊ី.ខេម ចូលទៅខាងការិយាល័យសហព្រះរាជអាជ្ញា។ ឯកសារហ្នឹងមានចំណងជើងជាភាសាអង់គ្លេសថាដូចតទៅនេះ “អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ការបង្ហាញជាអចិន្ត្រៃយ៍ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា”។

ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកដើម្បីបង្ហាញទំព័រចុងក្រោយនៃឯកសារមួយនេះ ដែលជារូបថតដែលត្រូវសាក្សីធ្វើការអត្ថាធិប្បាយកាលពីម្សិលមិញ ដែលមានរូបស្ត្រីម្នាក់យំនៅជិតសាកសពប្តីរបស់

គាត់។ ដូច្នេះលោកប្រធាន សូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញរូបភាពនេះនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១១:០៥:២២]

**កញ្ញា អង់តា ហ្គីសសេ៖**

រូបភាពនឹងបង្ហាញបន្តិចទៀត ពីព្រោះថាដោយសាររូបភាពនេះជារូបភាព ភីឌីអេហ្វ ដូច្នេះវាត្រូវការពេលវេលាបន្តិច។

សូមឲ្យបង្ហាញអក្សររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាផងនៅលើរូបថតនេះ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី អក្សររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាផងនៅលើរូបថតនេះ។ លោកសាក្សី លោកឃើញរូបថតនេះហើយ ហើយមានការអត្ថាធិប្បាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ រូបថតនេះចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ កាលពីម្សិលមិញនោះលោកបានបញ្ជាក់ថា "មុនពេលវាយយក -- រូបថតនេះថតនៅពេលមុនវ៉ៃយកទីក្រុងភ្នំពេញ គឺប្រហែលជា១ខែមុន" តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានទាក់ទងលោកទេ នៅពេលធ្វើការតាំងពិព័រណ៍រូបថតរបស់លោកនេះ គេមានទំនាក់ទំនងទៅកាន់លោកទេដើម្បីធ្វើការតាំងពិព័រណ៍រូបថតរបស់លោកនេះ?

**ឆ៖** ខ្ញុំគិតថាគួរតែមានការទាក់ទង ប៉ុន្តែមិនមានការទាក់ទងនោះទេ។ ដូច្នេះហើយខ្ញុំគិតថា យុនោះ -- ការសរសេរអក្សរនៅលើរូបថតនេះគឺខុស គឺមិនមែនថ្ងៃ១៧ មេសា នោះទេ ខ្ញុំគិតថាវាជាកំហុស ប៉ុន្តែខ្ញុំមិនអាចធ្វើអ្វីបាននោះទេទាក់ទងទៅនឹងកំហុសនេះ។ ខ្ញុំមានចេតនានៅសហការជាមួយនឹងខាងឯកសារកម្ពុជា ប៉ុន្តែខ្ញុំសូមអភ័យទោសដែលគេសរសេរអក្សរហ្នឹងវាខុស។

[១១:០៦:២៧]

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។ ឥឡូវនេះខ្ញុំចូលទៅប្រធានបទមួយផ្សេងទៀត។ អម្បាញ់មិញនេះលោកបានឆ្លើយជូនលោក វ៉ិចទ័រ កូប៉េ អំពីលក្ខខណ្ឌជីវភាពរបស់អ្នកភៀសខ្លួននៅទីក្រុងភ្នំពេញមុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។ ហើយលោកបានពន្យល់ថានៅក្នុងក្របខ័ណ្ឌនៃការងាររបស់លោកនោះគឺថាលោកធ្វើដោយស្ម័គ្រចិត្ត ដើម្បីថតរូបអំពីស្ថានភាពរបស់អ្នកភៀសខ្លួនមកទីក្រុងភ្នំពេញ។ ជាពិសេសលោកបានលើកឡើងអំពីអង្គការពីរ គឺកាកបាទក្រហម -- សូមទោស គឺបី គឺអង្គការទស្សនៈ

ពិភពលោក ហើយនិងអង្គការកាតូលិកសឺរីស។ សំណួររបស់ខ្ញុំដំបូងនោះ គឺថាតើលោកមានចាំថាមានអង្គការផ្សេងណាទៀតដែលធ្វើការពាក់ព័ន្ធទៅនឹងបញ្ហាជនភៀសខ្លួននៅសម័យនោះនៅក្នុងទីក្រុងភ្នំពេញ ហើយនិងនៅជុំវិញទីក្រុងភ្នំពេញដែរឬទេ?

[១១:០៧:៣៩]

**ឆ៖** នៅពេលនុំងគឺមានអង្គការតិចតួចប៉ុណ្ណោះដែលធ្វើការ ហើយចំពោះអង្គការដែលធ្វើហ្នឹង គឺថាចំពោះពាក្យថា "អង្គការក្រៅរដ្ឋាភិបាល" គឺមិនមែនជាពាក្យដែលគេប្រើនៅពេលនោះទេ។ ហើយមានបុគ្គលិកមួយចំនួនដែលធ្វើការនៅទីនោះ។ នៅពេលនោះគឺមិនមានភ្នាក់ងារច្រើនទេ គឺមិនមានភ្នាក់ងារច្រើនជួយសង្គ្រោះច្រើននោះឡើយ។

**ស៖** ពាក់ព័ន្ធទៅនឹងជនភៀសខ្លួនដដែល លោកបានឆ្លើយថា ចំនួននៅទីក្រុងភ្នំពេញនៅពេលវាយបែកនោះ គឺថាមានប្រហែលជា២លាន៤សែននាក់ ហើយលោកបានថតរូបជំរំ ថតអូតែល កាំបូឌី-យ៉ាណាជាដើម តើលោកមានបានដឹងអំពីបញ្ហាអនាម័យរបស់ហ្វូងប្រជាជនដ៏ច្រើនដែលអាចមាននៅក្នុងទីក្រុងដែរឬទេ?

**ឆ៖** ខ្ញុំគិតថាសំណួររបស់លោកស្រីចង់សួរថាតើមានបញ្ហាអនាម័យដែរឬទេ? គឺចម្លើយអត់មានទេ។ គឺស្ថានភាពហាក់ដូចជាមិនមានភាពអនាម័យអ្វីនោះឡើយ។ គឺនៅកន្លែងដែលមានប្រជាជនភៀសខ្លួនរាប់ពាន់នាក់នោះ គឺមានបញ្ហាអនាម័យយ៉ាងខ្លាំង។ ខ្ញុំគិតថា មិនមានអ្នកណាម្នាក់ពិភាក្សាជាមួយខ្ញុំទេ ខ្ញុំឃើញដោយខ្លួនឯង អត់មានអ្នកណាមកប្រាប់ខ្ញុំទេទៅលើបញ្ហានេះ។

[១១:០៩:៣២]

**ស៖** ការសូមបំភ្លឺពាក់ព័ន្ធទៅនឹងចំណុចនេះ គឺថាលោកនៅភ្នំពេញនៅចន្លោះឆ្នាំ១៩៧៣ ដល់ឆ្នាំ៧៥ តើលោកមានឃើញជនភៀសខ្លួននេះកើតឡើងយ៉ាងគំហុកតែម្តង ឬក៏កើតឡើងក្នុងរយៈពេលណាមួយនៅក្នុងចន្លោះឆ្នាំ៧៣ ដល់ឆ្នាំ៧៥ នេះ?

**ឆ៖** ជនភៀសខ្លួនកើតឡើងគឺថាបន្តិចម្តងៗ ប៉ុន្តែខ្ញុំអាចនិយាយថាមានចំនួនដល់ទៅរាប់លាន។ ជនភៀសខ្លួនគឺមកជាក្រុមៗ គេចចេញពីតំបន់ដែលមានការប្រយុទ្ធ ក៏ដូចជាតំបន់ដែលមានទម្លាក់គ្រាប់បែក។ ប៉ុន្តែមុនថ្ងៃ១៧ មេសា ប្រហែលជាប៉ុន្មានសប្តាហ៍គឺមានចំនួនប្រជាជនកើនឡើងយ៉ាងច្រើនដែលគាត់ជម្លៀសមកទីក្រុងភ្នំពេញ ព្រោះថានៅពេលនុំងគឺថាការវាយប្រយុទ្ធហ្នឹង គឺកាន់តែកៀកមកដល់ទីក្រុងភ្នំពេញហើយ ដូច្នេះប្រជាជនគាត់ព្យាយាម គាត់រត់គេចពីសង្គ្រាម គឺគាត់រត់ចូលមកទីក្រុង

ភ្នំពេញតែម្តង។ ដូច្នេះខ្ញុំអាចនិយាយបានថា ចំនួនប្រជាជនគឺកើនឡើងរហូតក្នុងពេលដែលខ្ញុំនៅទីក្រុងភ្នំពេញនេះ ប៉ុន្តែខ្ញុំមិនមានទិន្នន័យ ឬក៏មិនមានតួលេខឲ្យបានច្បាស់លាស់នោះទេ ប្រហែលជាមាននៅក្នុងឯកសាររបស់ខាងកាកបាទក្រហមអន្តរជាតិ គឺគេអាចស្ថិតិនេះបាន។

[១១:១១:១៦]

កាលពីម្សិលមិញខ្ញុំបានបញ្ជាក់រួចហើយថា ខ្ញុំថតរូបថតរបស់អង្គការ -- របស់កាកបាទក្រហមអន្តរាជាតិ -- អង្គរចននៃក្រហមអន្តរជាតិ ហើយវាមានទិន្នន័យបញ្ជាក់ថាវាមានទិន្នន័យថាមានប្រជាជនប្រហែលជា១លាននាក់ជាង ដែលជាជនភៀសខ្លួននោះ។ ប៉ុន្តែថាតើឯកសារនុំងគេទុកនៅបណ្ណសារណាមួយ ខ្ញុំមិនដឹងទេ។ ហើយប្រហែលជាមាននៅស្នាក់ការនៅប្រទេសស្វីស ឬមួយក៏យ៉ាងណានោះ ប្រហែលជាអាចមាន។ ប៉ុន្តែអ្វីដែលខ្ញុំបញ្ជាក់បាន គឺថាប្រជាជនជាជនភៀសខ្លួនរាប់ពាន់នាក់មិនបានចូលទៅតាមជំរំជនភៀសខ្លួននោះទេ គឺគាត់នៅរាយប៉ាយ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចូលទៅប្រធានបទផ្សេងទៀត គឺពាក់ព័ន្ធទៅនឹងថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ មានការពិភាក្សាគ្នាយ៉ាងវែងអន្លាយពាក់ព័ន្ធទៅនឹងបញ្ហានៃភាគីមួយ ឬច្រើនរបស់ខ្មែរក្រហមដែលលោកបានឃើញនៅពេលព្រឹក នៅថ្ងៃទី១៧ មេសា នោះ។ ឥឡូវនេះ ខ្ញុំព្យាយាមធ្វើឲ្យលោកមានការចងចាំ សំណួរដំបូង តើលោក នៅពេលដែលលោកទៅដល់ប្រទេសថៃនៅតាមក្បួនឡានទី២ ដែលចេញពីស្ថានទូតបារាំងនោះ តើលោកមាននឹកឃើញថាលោកបានរៀបរាប់អំពីបទពិសោធន៍របស់លោកនៅស្ថានទូតអាមេរិកប្រចាំទីក្រុងបាងកកដែរឬទេ?

[១១:១២:៥៣]

**ឆ៖** ខ្ញុំមិនមានមិត្តភក្តិ ឬក៏សហការីណានៅទូតអាមេរិកនៅបាងកកនោះទេ។ ខ្ញុំបានជួបជាមួយនឹងអ្នកសារព័ត៌មាននៅពេលដែលខ្ញុំឆ្លងកាត់ស្ពានចូលទៅក្នុងប្រទេសថៃ។ គឺជា -- នៅពេលនុំងគឺមានគេសម្ភាសខ្ញុំនៅខាងព្រំដែនថៃឆ្លងស្ពានចូលព្រំដែនថៃ គេសម្ភាសខ្ញុំប្រហែល៣០នាទី គឺលោកហ្វ័រេនស៊ី (តាមសំឡេងបកប្រែ) បានសម្ភាសខ្ញុំ ខ្ញុំចាំថានៅពេលនុំងគេថតរូបខ្ញុំ ហើយខ្ញុំៗទាញយកកាមេរ៉ារបស់ខ្ញុំដែលៗពេលនុំងគឺវាហាក់បីដូចជាការដែលគេបណ្តើមយកកាមេរ៉ា យករូបថត អ្វីរបស់ខ្ញុំយកទៅអ៊ីចឹងដែរ។ នេះគឺអ្វីដែលបានកើតឡើងចំពោះខ្ញុំ។ ចំពោះការសួររបស់គេនៅពេលនោះ គឺមិនមានជាអ្វីជាដុំកំភួនឡើយ វាគ្រាន់តែជាការសួរដោយមិនច្បាស់លាស់។ ហើយខ្ញុំបានប្រាប់គេថា បាទ។ គាត់សួរខ្ញុំថាតើលោកគិតថាមានចំនួនប្រហែលប៉ុន្មាន? ខ្ញុំឆ្លើយថា អ្នកណាដឹង ប្រហែលជារាប់ពាន់

រាប់ម៉ឺននាក់។ ហើយគេសួរថាតើការបង្ហូរឈាមហ្នឹងយ៉ាងម៉េចដែរ? ខ្ញុំមិនដឹងដែរ។ ខ្ញុំទទួលសំណួរមួយចំនួនប្រហែលជារក្សាទុកនៅបណ្ណាសារក្នុងស្ថានទូតអាមេរិក ហើយប្រហែលជាសាកលវិទ្យាល័យណាមួយអាចទទួលនូវចម្លើយនោះបាន។

**ស៖** សូមអភ័យទោសលោកសាក្សី ខ្ញុំគិតថាប្រហែលជាមានបញ្ហាបកប្រែ ខ្ញុំមិននិយាយអំពីការសម្ភាសជាមួយអ្នកកាសែតទេ។ ខ្ញុំចង់ ខ្ញុំសួរថាតើលោកធ្លាប់បានសម្ភាសជាមួយសមាជិកស្ថានទូតអាមេរិកនៅទីក្រុងបាងកកដែរឬទេ? គឺមិនមែនជាមួយនឹងមិត្តភក្តិរបស់លោកទេ គឺជាមួយសមាជិកស្ថានទូតអាមេរិកប្រចាំទីក្រុងបាងកក តើលោកមានចាំ ថាលោកមានការសម្ភាសបែបនេះទេ?

**ឆ៖** នៅភ្នំពេញអត់ទេ។ ប៉ុន្តែនៅបាងកក ខ្ញុំបានជួបជាមួយជនជាតិអាមេរិក ដែលធ្លាប់ធ្វើការនៅទូតអាមេរិកនៅភ្នំពេញ។ ខ្ញុំមិនគិតថាវាជាការសម្ភាសផ្លូវការនោះទេ យើងទៅជុំគ្នានៅផាត់ភុងយើងហូបស្រា ហូបបីយែបន្តិចបន្តួច យើងនិយាយអំពីសំណួរចុះឡើងៗទៅ។ ដូច្នេះ ខ្ញុំមិនគិតថាវាជាការសម្ភាស ឬក៏ការសួរចម្លើយអ្វីនោះឡើយ។ ខ្ញុំមិនមានទំនាក់ទំនងជាមួយនឹងអ្នកណាម្នាក់នៅស្ថានទូតអាមេរិកនោះ។

[១១:១៥:៥១]

**កញ្ញា អង់តា ហ្គិសសេ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញទូរលេខរបស់ស្ថានទូតអាមេរិកប្រចាំទីក្រុងបាងកក។ ឯកសារនេះមានតែជាភាសាអង់គ្លេសនោះទេ។ ហើយខ្ញុំចង់ប្រើប្រាស់សម្រង់ខ្លីមួយនៅក្នុងឯកសារនេះ ដូច្នេះសូមការអនុញ្ញាត ដើម្បីបង្ហាញឯកសារមួយនេះ គឺឯកសារលេខ D291/6.3.2.31 គឺ D291/6.3.2.31។ ERN ជាភាសាអង់គ្លេស 00495370។

ខ្ញុំឃើញថាខាងសហព្រះរាជអាជ្ញាងើបឈរ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

តាមដែលខ្ញុំដឹង ឯកសារនេះគឺមិនបានដាក់បញ្ចូលនៅក្នុងបញ្ជីរបស់ខាងមេធាវីការពារក្តី ហើយក៏មិនមាននៅក្នុងខាងបញ្ជីរបស់យើងដែរ។ ដូច្នេះ ខ្ញុំមិនដឹងថា តើខាងមេធាវីការពារក្តីបានដាក់ញត្តិ ឬក៏សារណាអ្វី ឬក៏មានលក្ខណៈបែបណានោះទេ។ យើងមិនជំទាស់ការប្រើប្រាស់ឯកសារនោះទេ ប៉ុន្តែ

យើងគ្រាន់តែចង់ឲ្យបញ្ជាក់ឲ្យបានច្បាស់ថា ឯកសារដែលមេធាវីការពារក្តីប្រុងប្រើប្រាស់នោះ គឺបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចទៅហើយ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបដោយខ្លី។ នេះមិនមែនជាឯកសារដែលយើងចង់ប្រើនោះទេ។ ផលប្រយោជន៍នៃឯកសារនេះ គឺថាដោយសារតែមានការស្តាប់ចម្លើយលោក រ៉ុកូហ្វ ដូច្នេះខ្ញុំសូមការបង្ហាញឯកសារនេះដើម្បីឲ្យ ចង់ដឹងថាតើគាត់នៅចងចាំដែរឬក៏អត់ ឬក៏មានបញ្ហាពាក់ព័ន្ធទៅនឹងទូរលេខមួយនេះ។ ដោយសារតែក្នុងឯកសារនេះមានលើកឈ្មោះរបស់គាត់ គឺរ៉ុកូហ្វ។ ដូច្នេះមានតែគាត់នេះហើយ ដែលអាចឆ្លើយតបបាន។ ហើយប្រសិនបើសហព្រះរាជអាជ្ញាមិនជំទាស់អ្វីទេ ខ្ញុំសូមប្រើនូវខ្លឹមសារខ្លីមួយនេះ ដើម្បីទទួលបានចម្លើយពីសាក្សី។

[១១:១៨:២៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១៩:៣៨]

**ប្រធានអង្គជំនុំ៖**

បាទ ដោយសារឯកសារដែលមេធាវីការពារក្តីលោក ខៀវ សំផន បានស្នើសុំនេះមិនមាននៅក្នុងបញ្ជីឯកសាររបស់ខ្លួន ក៏ដូចជានៅក្នុងបញ្ជីឯកសាររបស់ភាគីនានាដែលពាក់ព័ន្ធ ហើយអង្គជំនុំជម្រះធ្លាប់បានអនុវត្តរួចហើយ មិនអនុញ្ញាតឲ្យប្រើប្រាស់ឯកសារប្រភេទនេះក្នុងការសួរដេញដោលសាក្សី ឬក៏អ្នកជំនាញនោះទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមកត់សម្គាល់នូវការសម្រេចរបស់លោកប្រធាន។ ក៏ប៉ុន្តែនៅពេលដែលមានការស្នើសុំឲ្យបង្ហាញបញ្ជីឯកសារនោះ គឺថាមានការពាក់ព័ន្ធទៅនឹងសាក្សី ឈ្មោះរបស់គាត់មិនមាននៅក្នុងបញ្ជីសាក្សីរបស់យើងនោះទេ។ ដូច្នេះ ហេតុនេះហើយបានជាមិនមានឈ្មោះរបស់គាត់នៅក្នុងបញ្ជីរបស់យើង។ ខ្ញុំកត់សម្គាល់ទុកក៏ប៉ុន្តែជាការសោកស្តាយណាស់ដែលខ្ញុំមិនអាចបង្ហាញឯកសារនេះបាន។

[១១:២០:៤២]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសួរជាលក្ខណៈទូទៅ។ លោករ៉ុកូហ្វ មានឯកសារមួយគឺឯកសារទូរលេខរបស់ស្ថានទូត

អាមេរិក ហើយក្នុងនោះគេមានសរសេរឈ្មោះរបស់លោក ហើយក្នុងនោះក៏បានបញ្ជាក់ថា លោកក៏បានពន្យល់អំពីអ្វីដែលលោកបានឃើញ គឺថាមានឃើញភាគីបី គឺនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ ពាក់ព័ន្ធទៅនឹងភាគីបីនេះ តើវាជាអ្វីដែលលោកបានឆ្លើយទៅនឹងបុគ្គលិករបស់ស្ថានទូតអាមេរិកដែរឬទេ?

**លោក អាល់ រ៉ុក្កូហ្វ៖**

**ឆ៖** ខ្ញុំមិនបានប្រាប់បុគ្គលិកស្ថានទូតអាមេរិកនោះឡើយ។ ដូចដែលខ្ញុំបានបញ្ជាក់ប្រាប់លោកស្រីមុននេះហើយ គឺថាខ្ញុំគ្រាន់តែទៅហូបអីតិចតួចនៅផាត់ភុងជាមួយនឹងបុគ្គលិកទូតនៅខ្មែរទេ គឺបុគ្គលិកទូតនៅភ្នំពេញនោះទេ។ គឺថាខ្ញុំមិនបានប្រាប់អ្នកណាម្នាក់នៅទូតអាមេរិកនៅបាងកកនោះឡើយ។

ប្រសិនបើនិយាយអំពីការដែលទាហានខ្មែរក្រហមចូលមកទីក្រុងភ្នំពេញតាមបីកន្លែងឬក៏បីក្រុមនេះ គឺខ្ញុំមិនបាននិយាយឡើយ។ យើងមិនបាននិយាយអំពីកងវរសេនាតូច ឬក៏វរសេនាធំណាមួយនោះឡើយ ហើយខ្ញុំក៏មិនបានឃើញឯកសារហ្នឹងមុនពេលដែលលោកស្រីយកមកដាក់បង្ហាញនៅក្នុងសាលសវនាការបង្ហាញនៅក្នុងអេក្រង់នេះដែរ។ គឺខ្ញុំមិនបានដែរនិយាយអំពីបញ្ហានោះឡើយ។ ចំពោះបញ្ហាខ្មែររំដោះហ្នឹង គឺកើតឡើងប្រហែលជា១ឆ្នាំមុននឹងមកម្ល៉េះ។ ខ្ញុំមិនដឹងថាប្រភពឯកសារហ្នឹងមកពីណានោះទេ ប៉ុន្តែគាត់គួរតែ ឬក៏អ្នកសរសេរឯកសារហ្នឹងគួរតែរៀនឡើងវិញ ដើម្បីឲ្យវាមានភាពជាក់ស្តែង ឲ្យមានភាពត្រឹមត្រូវនូវការសរសេរឯកសារ។

[១១:២២:៥១]

**ស៖** សូមអរគុណចំពោះការឆ្លើយបំភ្លឺនេះ។ ឥឡូវខ្ញុំចូលទៅប្រធានបទមួយទៀត។ លោកបាននិយាយអំពីការទៅក្រសួងឃោសនាការនៅថ្ងៃទី១៧ ខែមេសា ដោយរួមជាមួយមិត្តភក្តិជាអ្នកសារព័ត៌មានរបស់លោក។ ហើយលោកក៏បានអត្ថាធិប្បាយទៅលើរូបថតដែលលោកបានថតកាលពីថ្ងៃនោះ។ សំណួរដំបូងរបស់ខ្ញុំពាក់ព័ន្ធទៅនឹងចំណុចនេះ។ ក្នុងចំណោមខ្មែរក្រហមដែលលោកបានឃើញនៅថ្ងៃនោះ តើមានអ្នកណាដែលលោកស្គាល់ទេនៅក្រសួងព័ត៌មានហ្នឹង នៅក្នុងចំណោមខ្មែរក្រហមដែលលោកបានឃើញនៅថ្ងៃនោះ?

**ឆ៖** អត់។

**ស៖** ក្នុងចំណោមខ្មែរក្រហមដែលលោកបានឃើញនៅថ្ងៃនោះ តើលោកឃើញតែជាយោធាទេ ឬក៏មានឃើញទាំងជនស៊ីវិលផងដែរ?

[១១:២៣:៤៩]

**ឆ៖** គឺមានបុគ្គលិកមួយចំនួនមកពីអតីតរបបលន់ នល់ គឺស្លៀកពាក់ជាសម្លៀកបំពាក់ស៊ីវិល មានប្រហែលជា១០, ២០នាក់។ ហើយមានមនុស្សប៉ុន្មាននាក់នៅជុំវិញនុ៎ង គឺស្លៀកពាក់ស៊ីវិលដូចដែលរូបថតខ្ញុំបង្ហាញម្សិលមិញអ៊ីចឹង គឺថាទាហានខ្មែរក្រហមឡើងជណ្ដើរចូលទៅក្នុងក្រសួង ហើយមានជនស៊ីវិលនៅជុំវិញ គឺបុរសម្នាក់ពាក់អាវពណ៌សហ្នឹង។ ដូច្នេះ ខ្ញុំគិតថាបុរសហ្នឹងគឺជាមនុស្សដែលធ្វើការនៅក្នុងក្រសួងហ្នឹង។ ហើយនៅព្រឹកនុ៎ង ហើយនៅពេលរសៀល នៅពេលដែលយើង នៅពេលខ្ញុំ ស៊ីដនី សាន់ប៊ឺជ ហើយ ចន ស្វេន ត្រូវបានគេដោះលែងពី -- ត្រូវបានគេយកពីស្ពានជ្រោយចង្វាមកកាន់ទីនោះដោយទាហានខ្មែរក្រហម គឺនៅពេលហ្នឹងគឺមានតែប៉ុណ្ណឹងនាក់។ ប៉ុន្តែខ្ញុំអត់ឃើញអ្នកណាម្នាក់ដែលខ្ញុំស្គាល់នោះទេ។

ចំពោះបញ្ហាដែលថាខ្មែរក្រហមស្គាល់ខ្ញុំ គឺបញ្ហាកើតឡើងនៅពេលក្រោយនោះទេ នៅថ្ងៃក្រោយនោះទេ ដែលនៅពេលនុ៎ងគឺមានទាហានខ្មែរក្រហមស្រែកហៅខ្ញុំពីលើឡានថា "លោក រ៉ុក្ខហ្វ។"។ ខ្ញុំក៏ឆ្ងល់នរណាស្គាល់ខ្ញុំ អ្នកណាគេដឹងពីខ្ញុំ ខ្ញុំមិនដែលស្គាល់អ្នកណាម្នាក់ផង។ ពេលនុ៎ង គាត់ទាហានហ្នឹងគឺស្លៀកពាក់ខោអាវគគ្រិច។ ខ្ញុំមិនដឹងថាតើអ្នកណានោះឡើយហើយពួកទាហាននុ៎ងមានប្រដាប់អាវុធទៀត។

[១១:២៥:២៣]

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់។ ឥឡូវនេះខ្ញុំចូលទៅប្រធានបទពីរចុងក្រោយរបស់ខ្ញុំ គឺខ្ញុំជិតបញ្ចប់ហើយ។ សំណួរតូចមួយដើម្បីសុំការបំភ្លឺពីលោក លោកបាននិយាយអំពីជីវិតរបស់លោកមុនពេលចេញដំណើរទៅថៃ គឺជីវិតរបស់លោកនៅក្នុងស្ថានទូតបារាំងនៅកម្ពុជា។ លោកបានបញ្ជាក់ថាលោក -- សម្រាប់ជាប្រភពព័ត៌មាននោះលោកមានវិទ្យុ គឺលោកអាចស្ដាប់វិទ្យុប៊ី.ប៊ី.ស៊ី បាន។ សំណួររបស់ខ្ញុំ តើក្រៅពីវិទ្យុ ប៊ី.ប៊ី.ស៊ី លោកទទួលបានព័ត៌មានពីប្រភពណាផ្សេងទៀតដែរឬទេ?

**ឆ៖** មិនមែននៅស្ថានទូតបារាំងទេ ប៉ុន្តែយើងមាន អាចមើលប្រតិចារឹកវិទ្យុបាន ពេលខ្លះគឺអ្នកសារព័ត៌មានបានប្រាប់មកខ្ញុំ។ ខ្ញុំមិនបានបើកដោយខ្លួនឯងទេឯកសារនេះ ប៉ុន្តែអ្នករួមការងារ ហើយខ្ញុំមិនអាចទៅស្ថានទូតសហរដ្ឋអាមេរិកដើម្បីរកព័ត៌មានទេ យើងមាន អេស.ប៊ី.អាយ.អេស ប្រតិចារឹករបស់ឯកសារហ្នឹង ដែលជាប្រតិចារឹករបស់វិទ្យុអន្តរជាតិ ដែលគេបានបញ្ជូនមកឲ្យខ្ញុំ។ ខ្ញុំអាចបានដឹងគឺថាសង្គ្រាមចប់ហើយ ហើយគឺថាមានការប្រកាសថា គេបានវិភាគទាន១លានដុល្លារដើម្បីឲ្យ ពេល

បញ្ចប់សង្គ្រាមដើម្បីកសាងប្រទេសកម្ពុជាថ្មី។ នេះហើយស្ថិតនៅក្នុងប្រតិចារឹករបស់ ហ្វីប៊ីស នេះឯង។ នេះជាអ្វីដែលថាស្ថានទូតអាមេរិកាំងដែលផ្សព្វផ្សាយ ដែលគេចាប់អារម្មណ៍នឹងប្រទេសនេះ ហើយវិទ្យុខ្មែរក្រហមក៏បានបកប្រែឯកសារនេះផងដែរ។

**ស៖** សូមអរគុណ។ សំណួររបស់ខ្ញុំគឺសំដៅទៅដល់ពេលដែលលោករស់នៅស្ថានទូតបារាំង គឺថាពេលដែលលោកស្នាក់នៅស្ថានទូតបារាំងនេះ តើលោកទទួលបានព័ត៌មានពីប្រភពណាខ្លះ ចាប់ពីថ្ងៃទី១៧ មេសា រហូតទៅដល់ដើមខែឧសភា ដែលលោកចេញទៅប្រទេសថៃនោះ?

[១១:២៧:៥២]

**ឆ៖** យើងនៅមានវិទ្យុរបស់យើង នៅពេលដែលថ្ងៃទី១ ខ្មែរក្រហមមកដល់ស្ថានទូតបារាំងដើរផែកផេររកវិទ្យុ ឬក៏ប្រដាប់គេហៅថា *"ត្រង់ស៊ីស្ទ័រ"* នោះ។ ហើយការណាយើងមានឧបករណ៍ផ្សាយវិទ្យុអីមិនអនុញ្ញាតហ្នឹងគេប្រមូលយក ហើយគេយកដាក់មួយគំនរនៅក្នុងទីធ្លា ហើយខ្មែរក្រហមមកដល់ ហើយធ្វើម៉េចកុំឲ្យមានការឧបករណ៍ដែលទាក់ទង បញ្ជូន ហើយនិងទទួលបាន។ ដូច្នេះគេប្រមូលយក។ ហើយយើងមានការផ្សព្វផ្សាយពីវិទ្យុ អំពីស្ថានទូតគឺថានៅខាងជើង ហើយនិងនៅស្ថានទូតកូរ៉េដែលមានថាមពលអគ្គិសនី ហើយនៅស្ថានទូតបារាំងក៏ទៅមាន -- នៅមានភ្លើងក៏គេ-- រហូតដល់ចុងបញ្ចប់។ យើងមានវិទ្យុ ខ្ញុំអាចស្ដាប់វិទ្យុ គេហៅ*"ស្សូតវេវ"* –រលកសំឡេងខ្លីហ្នឹង– គឺថាស្ដាប់ ប៊ី.ប៊ី.ស៊ីឮបាន ហើយវិទ្យុសំឡេងសហរដ្ឋអាមេរិកក៏ស្ដាប់បានដែរ។ ហើយគឺនិយាយពីហេតុការណ៍ទាន់ -- ទាន់ហេតុការណ៍នោះឯងរឿងរ៉ាវនោះ គឺយើងស្ដាប់បានតែប៉ុណ្ណឹង។ គឺយើងមិនស្ដាប់បានទូទៅទាំងអស់ទេ គឺថាមានតែក្នុងបរិវេណដែលយើងនៅទេ ដែលអាចស្ដាប់បានព្រោះយើងមានចរន្តអគ្គិសនី។

[១១:២៨:២១]

**ស៖** ប្រធានបទចុងក្រោយ។ លោកបានលើកអំពីការងារជាអ្នកថតរូបឯករាជ្យ គឺមានន័យថាលោកធ្វើការជាមួយសារព័ត៌មានជាច្រើន។ អម្បាញ់មិញនេះលោកនិយាយអំពីសារព័ត៌មានញូវយ៉កថាមស៍ ហើយនិងញូវស្វីក។ ខ្ញុំចង់ដឹងថា តើលោកស្គាល់អ្នកកាសែតញូវស្វីក ដែលមានឈ្មោះថា ហ្វេរីឡៃ គឺ អេហ្វ-អា-អ៊ីការិច- វីឡៃ ឬក៏ វីឡៃ ខ្ញុំមិនដឹងច្បាស់ទេ គឺថា វេ-អ៊ី-អិលពីរ-អ៊ី-អ៊ីការិច។ គឺ ប៉ុលប្រ៊ីងយ័រវីដ្ឋ (តាមសំឡេងបកប្រែ) តើលោកមានស្គាល់ឈ្មោះអ្នកទាំងពីរនេះទេ?

**ឆ៖** ឈ្មោះទី១ ខ្ញុំអត់ស្គាល់ទេ។ ហើយឃើញថា មានអ្នកឆ្លើយឆ្លងព័ត៌មានជាច្រើនដែលធ្វើឲ្យទស្សនាវដ្ដីមួយៗ ពេលខ្លះគឺថាគេចេញចូល។ ឈ្មោះទី២ ខ្ញុំតាមមិនទាន់ទេ លោកស្រីអានលឿនពេក

ឈ្មោះមនុស្សទី២។

**ស៖** ប៉ូល ប្រ៊ីងឃ្លេរ៉ូជឺ។ ខ្ញុំអានដូចជាមិនសូវត្រូវទេ សូមអភ័យទោសផងលោកសាក្សី។

**ឆ៖** ខ្ញុំមិនដឹងស្គាល់អ្នកណាដែលឈ្មោះនោះទេ។ ខ្ញុំស្គាល់ ផូល ប្រ៊ីងគី-រ៉ូជឺ (Paul Brinkley-Rogers) នេះជាឈ្មោះមនុស្សដែលលោកស្រីសួរហ្នឹង ខ្ញុំដូចជាមិនស្គាល់។

[១១:៣១:០៥]

**ស៖** បាទ គាត់ជាអ្នកកាសែតដែលធ្វើការឲ្យសារព័ត៌មានញូវស្វីក ព្រោះថាលោក លោកបានឆ្លើយថាក៏ធ្វើការឲ្យញូវស្វីកដែរ។ អ៊ីចឹងខ្ញុំចង់ដឹងថា លោកធ្លាប់មានសហការធ្វើការងារអ្វីជាមួយនិងអ្នកសារព័ត៌មានទាំងពីរនាក់ហ្នឹងទេ។

**ឆ៖** ខ្ញុំមិនដឹងថាអ្នកទី១ ឈ្មោះអី អ្នកណាទេ។ ហើយខ្ញុំទាក់ទងជាមួយ ផូល ប្រ៊ីងហ្គ័រ-រ៉ូជឺ (Paul Brinkley-Rogers) ហើយខ្ញុំមិនដឹងថា គេធ្វើការឲ្យអង្គការណាទេ គឺប៉ុន្តែយើងបានទំនាក់ទំនងជាមួយគាត់ គេថតជាខ្សែភាពយន្ត ប៉ុន្តែយើងមានការរៀបចំ ជួនកាលក៏អត់។ ខ្ញុំមិនដែលធ្វើការឲ្យញូវយ៉កថៃមស៍ទេ។ ខ្ញុំបានផ្ដល់រូបថតពីរបីតែប៉ុណ្ណោះ។ កាលណាមានអ្នកឆ្លើយឆ្លងមកដល់ទីក្រុង គេត្រូវតាមដានព័ត៌មានលើរឿងមួយចំនួន គេចង់បាន ហើយគេចង់បានព័ត៌មានទាន់ហេតុការណ៍ពេលនោះហើយដែលយើងសន្ទនាគ្នា។ ហើយជាពិសេស គឺខ្ញុំជាភ្នែកជាច្រមុះរបស់អ្នកទាំងអស់ហ្នឹង កាលណាគេមកជួបគេមកជួបខ្ញុំគេចាប់អារម្មណ៍ បើថាដូចជា ដូចជាថាដូចជាឆ្កែមួយអ៊ីចឹង គឺថាកាលណាមានអីក្លិនចម្លែក គឺថាកន្ទុយបក់ បានន័យថាគេចាប់អារម្មណ៍មកចង់ជួបយើងអ៊ីចឹង។ នេះហើយគឺថា យើងអាចនឹងទៅជាមួយគេ ២-៣ថ្ងៃបែបនោះ។

[១១:៣២:៣៦]

ខ្ញុំធ្វើអ្វីដែលខ្ញុំត្រូវធ្វើ ហើយខ្ញុំពិភាក្សាជាមួយដូចជា អេដ ប្រេដលី (Ed Bradley) មកពី ស៊ី.ប៊ី.អេស ដើម្បីធ្វើការងារ២-៣ថ្ងៃ ហើយក្រោយមកសម្រាប់ញូវយ៉កថៃមស៍ដែលគាត់មកធ្វើ។ ហើយស៊ី.ប៊ី.អេស ជាអ្នកនិពន្ធនាយកជាដើមមកពី ខននិចទីខាត់(Connecticut) នៅញូវយ៉កថៃម ហើយគាត់បានឃើញនូវរឿងរ៉ាវ ហើយគាត់ចង់បាន ស៊ី.ប៊ី.អេស ថតខ្សែភាពយន្តសម្រាប់ស៊ីប៊ីញូវស៍។ ហើយ ស៊ីដនី គាត់សរសើរអ្វីខ្ញុំធ្វើទេ គឺថាអត់ទេ យើងមានបញ្ហា។ គឺថាដូចដែលយើងដឹងហើយថាយើងធ្វើការជាមួយតែ សាន់ប៊ឺជ ហើយខ្ញុំធ្វើការឲ្យអ្នកណាដែលគេអ្នកចង់ដឹងពីខ្ញុំក្នុងសហគមន៍សារព័ត៌មាន ខ្ញុំមិនធ្វើការឲ្យអ្នកណាជាក់លាក់ទេ។ ខ្ញុំជាអ្នកធ្វើការឯករាជ្យ ខ្ញុំអាចនឹងចង់តែលក់រូបថត

មួយពីរបីទៅឲ្យ អាសូស៊ីអេតធីត ប្រេស ជាពិសេស ញូវស្វីក ក៏ផងដែរ។ ប៉ុន្តែគេមិនដែលចាត់ទុកថា ខ្ញុំជាបុគ្គលិកគេទេ។ ខ្ញុំដូចថា លក់រូបថតអីជាដើម ញូវយ៉កថែមស៍ជាដើម ញូវស្វីកជាដើម ហើយនិង ថែមស៍ សារព័ត៌មានថែមស៍នោះ គឺមាន។

[១១:៣៣:៤២]

**ស៖** លោក រ៉ុកូហ្វ នេះជាសំណួរចុងក្រោយរបស់ខ្ញុំពាក់ព័ន្ធទៅនឹងលោក ផូល ប្រ៊ីងឃ្លី-រ៉ូជ័រ នោះ តើគាត់មានវត្តមាននៅជាមួយលោកនៅស្ថានទូតបារាំងនៅចន្លោះថ្ងៃទី១៧ មេសា ហើយនិងដើម ខែឧសភា ឆ្នាំ៧៥ ដែរឬទេ?

**ឆ៖** ផូល ប្រ៊ីងឃ្លី-រ៉ូជ័រ មិននៅក្នុងកម្ពុជាមុនពេលដួលរលំភ្នំពេញទេ ហើយមានអាមេរិកតែ ប្រាំបីនាក់ទេនៅស្ថានទូតបារាំង។ ដូច្នេះហើយគឺថា ខ្ញុំស្គាល់ ផូល ប្រ៊ីងឃ្លី-រ៉ូជ័រ នេះគឺថា គាត់មិនបាន នៅភ្នំពេញទេ ក្នុងពេលដែលភ្នំពេញដួលរលំនោះ។

[១១:៣៤:៤៦]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោក រ៉ុកូហ្វ ដែលបានចំណាយពេលវេលាឆ្លើយទៅនឹងសំណួររបស់ខ្ញុំ សូមឲ្យ លោកត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោក អាល់ រ៉ុកូហ្វ ការស្តាប់សក្ខីកម្មរបស់លោករហូតមកដល់ពេលនេះ បាន ចប់ហើយ។ វត្តមានរបស់លោកនៅអង្គជំនុំជម្រះនេះលែងមានភាពចាំបាច់ទៀតហើយ លោកអាចវិល ត្រឡប់ទៅកាន់ទីលំនៅរបស់លោក ឬក៏គោលដៅណាដែលលោកចង់ទៅបានហើយ។ អង្គជំនុំជម្រះសូម អរគុណចំពោះលោក ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួមផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំ ជម្រះក្នុងរយៈពេល១ថ្ងៃកន្លះកន្លងមកនេះ ប្រកបដោយភាពអត់ធ្មត់ ខិតខំអស់ពីលទ្ធភាព សមត្ថភាព របស់ខ្លួន។ លោក រ៉ុកូហ្វ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ។ សូមលោក អាល់ រ៉ុកូហ្វ ជួបតែសំណាងល្អ រស់នៅប្រកបដោយសេចក្តីសុខ សុភមង្គល ហើយនិងវិល ត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូន សាក្សី រូបនេះវិលត្រឡប់ទៅកាន់លំនៅស្ថានរបស់គាត់ ឬក៏ទីកន្លែងណាដែលជាគោលដៅគាត់មាន

បំណងចង់ទៅបានហើយ។

លោក អាល់ រ៉ុកូហ្វ អាចចាកចេញពីបន្ទប់សវនាការត្រឡប់ទៅបានហើយ។

[១១:៣៥:៥៨]

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

[១១:៣៦:១៩]

**ប្រធានអង្គជំនុំ៖**

ម៉េចទៅលោកស្រីមេធាវីមានបញ្ហាអីទេ?

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំមានពីរចំណុចទៀតដែលត្រូវនិយាយ។ ចំណុចទី១ គឺថាចង់បន្តអំពីការកត់សម្គាល់របស់ខ្ញុំទៅលើបញ្ជីរបស់ភាគី ខ្ញុំចង់ជម្រាបជូនអង្គជំនុំជម្រះនូវឯកសារ E9/27 ដែលជាសំណើរបស់ក្រុមមេធាវី អៀង ធីរិទ្ធ ដែលនៅកថាខណ្ឌទី៤ នៃឯកសារហ្នឹងគឺមានអ៊ីម៉ែលរបស់ ស៊ូហ្សានឡេម ចុះថ្ងៃទី០៤ មេសា ឆ្នាំ២០១១ ដែលៗចែងថា "ភាគីមិនមានកាតព្វកិច្ចក្នុងការដាក់ឯកសារទេ ឯកសារទាក់ទងទៅនឹងអ្នកដែលភាគីផ្សេងៗស្នើហៅ" ដូច្នេះជាចំណុចមួយដែលខ្ញុំចង់សង្កត់ធ្ងន់ គឺថាទាក់ទងទៅនឹងការចោទសំណួរទៅសាក្សីផ្សេងៗទៀតនោះ គឺថាយើងនឹងជួបប្រទះការលំបាកដដែល ពាក់ព័ន្ធទៅនឹងបញ្ជីឈ្មោះសាក្សីនេះដែលយើងមិនបានស្នើឲ្យកោះហៅ។ ដូច្នេះ នៅក្នុងការពាក់ព័ន្ធនឹងឯកសារនៅក្នុងសំណុំរឿងនោះ គឺថាវាគួរឲ្យសោកស្តាយណាស់ ដែលយើងមិនអាចប្រើឯកសារខ្ញុំអម្បាញ់មិញនេះ ឧទាហរណ៍នេះ។

[១១:៣៧:៤១]

ចំណុចទី២ លោកប្រធានដូចដែលខ្ញុំបានលើកកាលពីម្សិលមិញហើយ គឺថាលោក ខៀវ សំផន គាត់អស់កម្លាំងនៅឡើយ ទើបតែចេញពីមន្ទីរពេទ្យ ដូច្នេះគាត់ចង់សុំបញ្ជាក់ថាគាត់លះបង់សិទ្ធិចូលរួមសវនាការប្រជុំលើឯកសារស្អែក ដូច្នេះគាត់សុំអនុញ្ញាតសម្រាកនៅក្នុងមន្ទីរឃុំឃាំង ដើម្បីឲ្យសុខភាពគាត់ប្រសើរ ដើម្បីចូលរួមក្នុងការចោទសំណួរទៅសាក្សីខាងមុខទៀត។ ដូច្នេះ ខ្ញុំនឹងដាក់សំណើនេះហើយយើងបានធ្វើលិខិតសុំលះបង់សិទ្ធិទាក់ទងសវនាការលើឯកសារហើយ ហើយៗកាលលើកមុននេះបើអីចឹងសម្រាប់ស្អែក និងខានស្អែកនេះ យើងក៏ធ្វើដូចគ្នាអីចឹងដែរលោកប្រធាន។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងឆ្លើយដោយសង្ខេបទាក់ទងទៅនឹងបញ្ហាដែលមេធាវីបានលើកអំមិញអំពីដំណើរការឯកសារនោះ គឺថាមេធាវីគប្បីតែយល់ថាជានីតិវិធី ប្រសិនបើខ្លួនចង់ប្រើឯកសារ។ ពួកគាត់ត្រូវតែដាក់សំណើទៅក្រឡាបញ្ជី ដោយបញ្ជាក់ឲ្យច្បាស់។ ជំហររបស់យើងខ្ញុំគឺថា យើងមិនជំទាស់នៅពេលដែលមេធាវីការពារក្តីកំណត់អត្តសញ្ញាណសាក្សីដែលទាក់ទងទៅនឹងសាក្សី ហើយប្រើនីតិវិធី ហើយដាក់ចំពោះមុខអង្គជំនុំជម្រះ។ ចំណុចដែលខ្ញុំក្រោកឈរឡើងនោះគឺថាតុលាការបានជ្រាបហើយ ថាមិនមែនជាឯកសារដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង។ ផ្ទុយទៅវិញ ខ្ញុំសូមកត់សម្គាល់ថាទោះបីជាយើងធ្វើ ប្រឹង កិច្ចប្រឹងប្រែងដ៏ល្អសម្រាប់កំណត់អត្តសញ្ញាណ អ្វីៗដែលយើងព្យាយាមនឹងពន្យល់ និងដាក់សំណើនោះ គឺថាមេធាវីលោក ខៀវ សំផន តែងតែជំទាស់។ ទោះបីជាដូច្នោះក៏ដោយ ទោះបីជាមេធាវីការពារក្តីលោក ខៀវ សំផន គោរពតាមនីតិវិធីសត្រឹមត្រូវនោះ យើងមិនមានការជំទាស់នោះទេ នៅពេលដែលគេកំណត់អត្តសញ្ញាណឯកសារដែលទាក់ទងនឹងសាក្សី។ ដូច្នេះ ខ្ញុំសូមកែតម្រូវប្រតិចារឹករបស់តុលាការ ដែលមេធាវីការពារក្តីបានលើកខាងដើមអម្បាញ់មិញនេះ។

សូមអរគុណលោកប្រធាន។

[១១:៤០:១៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៥:២១]

**ប្រធានអង្គជំនុំ៖**

បាទ បន្ទាប់ពីបានស្តាប់នូវបញ្ហាដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ឯកសារពិភាក្សាដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ។ អង្គជំនុំជម្រះប្រកាន់ជំហរយ៉ាងជាក់ច្បាស់ថា អនុវត្តដូចកិច្ចដំណើរការនីតិវិធី ដែលអង្គជំនុំជម្រះធ្លាប់បានកំណត់កន្លងមក ហើយបានបង្ហាញបញ្ជាក់បន្ថែមដោយតំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះ គឺជាការបញ្ជាក់ដ៏ត្រឹមត្រូវហើយលើការដាក់បង្ហាញឯកសារយកមកពិភាក្សាដេញដោលចំពោះមុខអង្គជំនុំជម្រះ។

ហើយចំពោះសំណើសុំរបស់លោកមេធាវីការពារក្តី លោកស្រីការពារក្តីលោក នួន ជា អ៊ំ!

លោក ខៀវ សំផន ចំពោះការលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃស្អែក ឬនិងថ្ងៃខានស្អែក វាអាស្រ័យទៅលើកិច្ចដំណើរការសវនាការ ដែលយើងនឹងប្រព្រឹត្តទៅនៅពេលខាងមុខនេះ លើបញ្ហានេះ អង្គជំនុំជម្រះនឹងពិនិត្យពិចារណា ហើយជូនដំណឹងទៅមេធាវីការពារក្តី និងលោក ខៀវ សំផន នៅពេលវេលារសៀលនេះ ដោយអង្គជំនុំជម្រះនឹងបង្គាប់ឲ្យគ្រូពេទ្យដែលទទួលបន្ទុកក្នុងការពិនិត្យថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក នេះពិនិត្យសុខភាពរបស់គាត់សាជាថ្មីម្តងទៀត ហើយរាយការណ៍ជូនមកអង្គជំនុំជម្រះ។ អង្គជំនុំជម្រះបានព័ត៌មាននេះធ្វើមូលដ្ឋាន ដើម្បីជាមូលដ្ឋានក្នុងការសម្រេចលើបញ្ហានេះ។

[១១:៤៦:៥៦]

បាទ ជាបន្តនេះ អង្គជំនុំជម្រះសូមលើកបញ្ហាមួយទៀតយកមកពិភាក្សាជាមួយនឹងភាគីអំពីប្រធានបទនៃការដាក់បង្ហាញឯកសារគន្លឹះនានាពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ។ ទី១ អង្គជំនុំជម្រះចង់សួរទៅតំណាងសហព្រះរាជអាជ្ញាថា តើតំណាងសហព្រះរាជអាជ្ញាបានរៀបចំនូវកិច្ចដំណើរការនៃការដាក់ឯកសារបង្ហាញឯកសារពាក់ព័ន្ធនឹងប្រធានបទនេះរួចរាល់ហើយឬនៅ? ហើយថាតើប្រសិនបើត្រូវការបង្ហាញនោះ តើត្រូវចំណាយពេលវេលាប៉ុន្មានដែរ?

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ អ្វីដែលខ្ញុំយល់ គឺយើងបានរៀបចំ កំពុងរៀបចំដើម្បីចាប់ផ្តើមព្រឹកថ្ងៃពុធ ហើយនិងអ្វីដែលយើងខ្ញុំគ្រោងនោះ គឺថារយៈហ្នឹងគឺថា២ថ្ងៃសរុប ហើយយើងនឹងចាប់ផ្តើមជាមួយឯកសារទាក់ទងពីតួនាទីរបស់លោក អៀង សារី បន្ទាប់មកមកលោក ខៀវ សំផន ហើយយើងបញ្ចប់ពីតួនាទីរបស់លោក នួន ជា។ ខ្ញុំមិនបានទាន់ប្រាកដទេថា តើតុលាការតម្រូវឲ្យយើងខ្ញុំចាប់ផ្តើមល្ងាចនេះដែរឬយ៉ាងដូចម្តេច? ខ្ញុំមិនប្រាកដទេ ប៉ុន្តែផែនការរបស់យើងខ្ញុំ គឺថាចង់ចាប់ផ្តើមព្រឹកថ្ងៃស្អែកគឺឯកសារទាក់ទងទៅនឹងជនជាប់ចោទ អៀង សារី អំពីតួនាទីរបស់គាត់។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ចុះខាងក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងប្រធានបទនេះយ៉ាងម៉េចដែរ?

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ចំពោះយើង យើងមិនចង់បង្ហាញឯកសារទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទនៅពេលនេះទេ

យើងចង់ស្តាប់សាក្សី ហើយនិងអ្នកជំនាញសិន -- ដើមបណ្តឹងរដ្ឋប្បវេណីសិន។ ហើយយើងនឹងបង្ហាញឯកសាររបស់យើង ក្រោយពីស្តាប់ពួកគាត់ទាំងអស់គ្នា។ យើងមិនទាន់បង្ហាញឯកសារបានទេនៅសប្តាហ៍ក្រោយ យើងសុំលើកទៅពេលក្រោយទៀត។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ចុះខាងក្រុមមេធាវីការពារក្តីលោក នួន ជា តើមានឯកសារត្រូវដាក់បង្ហាញពាក់ព័ន្ធនឹងប្រធានបទនេះដែរឬទេ នៅក្នុងអំឡុងពេលនៃការធ្វើសវនាការលើប្រធានបទនេះ?

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន យើងខ្ញុំមានការលំបាកក្នុងការជូនដំណឹងជាគំនិតថាតើយើងខ្ញុំប្រកាន់ជំហរអ្វី ហើយយើងនឹងពិនិត្យមើលកូនក្តីរបស់ខ្ញុំល្ងាចនេះ។ យើងបានទទួលរបាយការណ៍ថា គាត់បានធូរស្រាលបន្តិច គឺយើងអាចណែនាំយើងខ្ញុំបានអំពីគំនិតនេះ ហើយយើងគ្រោងថា បើសិនជាយើងខ្ញុំមានការជំទាស់ ឬក៏សេចក្តីសន្និដ្ឋានអ្វីនឹងលើកឡើង ហើយយើងនឹងលើកឡើងក្នុងជាឯកសារលាយលក្ខណ៍អក្សរដូចខ្ញុំជម្រាបលោកប្រធានអង្គជំនុំជម្រះពីកាលមុនដូច្នោះដែរ។

[១១:៥០:៣៧]

**ប្រធានអង្គជំនុំ៖**

អរគុណដែលបានផ្តល់ព័ត៌មានដូច្នេះ។ ចុះក្រុមមេធាវីការពារក្តីលោក អៀង សារី?

**លោក អាង ឧត្តម៖**

សូមគោរពតុលាការ សូមគោរពភាគី សួស្តីអស់លោកអ្នកទាំងឡាយដែលបានចូលរួម។ គោលជំហររបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ក៏មិនខុសពីក្រុមលោក នួន ជា ប៉ុន្មានដែរ។ ទី១ យើងត្រូវតែបានទទួលការណែនាំពីលោក អៀង សារី សិន ថាតើយើងធ្វើយ៉ាងម៉េច។ ហើយខ្ញុំប្រហែលជាមានគំនិតដែលគិតថា ការធ្វើដេញដោលលើឯកសារទាក់ទងនេះប្រហែលជាលឿនពេក ប្រហែលជាឆាប់ពេក ប្រហែលយើងមិនដឹងត្រៀមរៀបចំយ៉ាងម៉េចឲ្យទាន់ពេលវេលា។ តែយ៉ាងណាក្តីយើងត្រូវការពិភាក្សាជាមួយលោក អៀង សារី សិនមុននឹងផ្តល់ព័ត៌មានជាក់លាក់ពីបញ្ហានេះ។ តែនៅពេលនេះយើងអត់បានពិភាក្សាជាមួយគាត់នៅឡើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះក្រុមមេធាវីការពារក្តីលោក ខៀវ សំផន?

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ចំពោះក្រុមមេធាវីការពារឲ្យលោក ខៀវ សំផន គោលជំហររបស់យើងច្បាស់លាស់ណាស់ យើងនឹងមិនបង្ហាញឯកសារនៅក្នុងឯកសារនេះទេ។ ពីព្រោះយើងយល់ឃើញថា បើសិនជាយើងមានឯកសារនឹងបង្ហាញនោះ យើងត្រូវតែនិយាយតវ៉ា ជជែកដេញដោល តែឥឡូវនេះវាមិនទាល់ដល់ពេលជជែកដេញដោលគ្នានោះទេ។ អ៊ីចឹងយើងអត់មានឯកសារអ្វីត្រូវបង្ហាញទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវព័ត៌មានផ្សេងដែលភាគីបានផ្តល់នៅពេលនេះ។

ឥឡូវនេះសវនាការនៅថ្ងៃនដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី៣០ ខែមករា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការអំពីការដាក់បង្ហាញឯកសារភស្តុតាងគន្លឹះនានាពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ ដោយតំណាងសហព្រះរាជអាជ្ញា និងការធ្វើអត្ថាធិប្បាយ ឬ/និងការជំទាស់ និងការឆ្លើយតបទៅនឹងការជំទាស់ផ្សេងៗរបស់ភាគីពាក់ព័ន្ធ។ សូមភាគី និងសាធារណជនជ្រាប។

[១១:៥៣:០៥]

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីរ គឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឲ្យនាំខ្លួនលោក អៀង សារី ត្រឡប់មកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យមុនម៉ោងប្រាំបួន ដោយទុកឲ្យគាត់នៅបន្ទប់ឃុំខ្លួនពីខាងក្រោមសាលសវនាការនេះ ដោយរៀបចំទុកឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ចំណែកឯលោក ខៀវ សំផន រង់ចាំស្តាប់ការសម្រេចរបស់អង្គជំនុំជម្រះនៅរសៀលនេះ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១១:៥៣ នាទី)*